# សច្ចធម៌

## និង

# ពុទ្ធិកតិបណ្ឌិត


រចនា ចងក្រង និង រៀបរៀង ដោយ

ព្រហ្ម~មេត្តា (ហៅ ជយវរិន្ទ)



ការផ្សាយរបស់មណ្ឌលពុទ្ធិត្រៃគុណ

ព. ស. ២៥៤៩ (2005)

# សច្ចធម៌

# និង

# ពុទ្ធិគតិបណ្ឌិត

ប្រមូល រៀបរៀង ចងក្រង ដោយ **ព្រាហ្ម មេត្តា**

ការផ្សាយរបស់ **មណ្ឌលពុទ្ធិ "ត្រៃគុណ"**

**ព.ស. ២៥៤៩**

---

**គ.ស. ២០០៥**

# វិភាគទាននៃការពិចារណា...

# ការស្វែងរក

## សច្ចធម៌ និង ពុទ្ធិគតិបណ្ឌិត

## សម្រាប់

# គ្រប់គ្រង អប់រំ ទូន្មានជីវិត

## ...រៀនរស់ និង រៀនស្លាប់...

# ទាចារអ្នករៀបរៀង

ជាបឋម ខ្ញុំបាទ **ព្រហ្ម មេត្តា** សូមសំដែងនូវការគោរពដ៏ស្មោះស្ម័គ្របំផុតចំពោះអស់លោក-អ្នកដែលកំពុងកាន់កូនសៀវភៅនេះអាន ។ តាមពិត ខ្ញុំបាទមិនមែនជាអ្នកចេះដឹងជ្រាលជ្រៅអ្វីប៉ុន្មានទេ ខាងផ្នែកព្រះធម៌វិន័យនោះ ។

តែការដែលខ្ញុំខិតខំព្យាយាម អំណត់ខន្តី សំភី ប្រើប្រាស់ពេលវេលាដ៏មានតម្លៃ និង ការយល់ដឹងតិចតួចស្តួចស្តើងរបស់ខ្លួន ដើម្បីចងក្រង និង រៀបរៀងកូនសៀវភៅនេះឡើង គឺក្នុងគោលបំណងចូលរួមវិភាគទានជាមួយរៀមច្បងទាំងឡាយ ប្រមែប្រមូលនូវកេរ្តិ៍មរតកក្បួនខ្នាតដីកាធម៌អាថ៌ របស់បុព្វគ្រូអាចារ្យ រៀមច្បងមកចងក្រងដោយសង្ខេបនូវគតិបណ្ឌិតទាំងឡាយ នូវអរិយសច្ចធម៌ ដែលព្រះសម្មាសម្ពុទ្ធជាព្រះបរមគ្រូនៃយើងរាល់គ្នា លោកទ្រង់បានរកឃើញ និង ត្រាស់ដឹងនូវគុណធម៌ដ៏កំពូលទាំងឡាយ ដែលចាត់ទុកជាប្រទីបបំភ្លឺផ្លូវជីវិតមនុស្សគ្រប់គ្នា សម្រាប់ជាគុណប្រយោជន៍ជាមេរៀនជីវិត សម្រាប់ការរស់នៅក្នុងនាវាត្រៃលក្ខណ៍នេះ ( **អនិច្ចំ ទុក្ខំ អនត្តា** ) កុំអោយលង់វង្វេងស្រវឹងនឹងតណ្ហា អវិជ្ជា ឧបាទាន ដែលជាប្រភពនៃសេចក្តីទុក្ខទាំងឡាយនោះ ។

ខ្ញុំព្រះករុណា - ខ្ញុំបាទ ក៏សូមការអភ័យទោសផងដែរ ពីសំណាក់ព្រះសង្ឃ អស់លោក-អ្នក រៀមច្បងជាអ្នកប្រាជ្ញ រាជបណ្ឌិត អក្ខកោវិទទាំងឡាយ ដែលមានការចេះដឹងទូលំទូលាយ ខាងផ្នែក

# សច្ចធម៌ និង ពុទ្ធិគតិបណ្ឌិត

ព្រះធម៌វិន័យ សូមមេត្តាខន្តីអភ័យទោសចំពោះការខ្វះខាតទាំងឡាយណា...**ប្រសិនបើមាន**... តែតាមការពិតនោះប្រាកដជាមាន ទោះបីជាខ្ញុំព្រះករុណា ខ្ញុំបាទគ្មានចេតនាបំណងក៏ដោយ ព្រោះថាការធ្វើ និង ការខ្វះខាតរមែងមានជាប់នៅជាមួយគ្នាជានិច្ច។ នៅក្នុងលោកនេះ គ្មានអ្វីដែលល្អឥតខ្ចោះ ឥតខ្វះចន្លោះនោះឡើយ ។ សូម្បីតែការមិនធ្វើអ្វីសោះនោះ ក៏មិនប្រាកដថាគ្មានកំហុសនោះដែរ ។ តាមពិតនិយាយដោយសុភាពរាបសា និងដោយសេចក្តីស្មោះសរ កំហុសគឺជាកញ្ចក់សម្រាប់ឆ្លុះបញ្ចាំង នូវសមត្ថភាពមនុស្សទៅវិញទេ ។ ប្រការសំខាន់ ត្រង់ការដែលយើងចេះទទួលស្គាល់កំហុស ហើយរៀនសូត្រពីកំហុសនោះ និង កុំអោយកំហុសដដែល ៗ នោះ កើតឡើងជាថ្មីដដែល។ ឡើងវិញ ។

ដោយខ្ញុំបាទសង្កេតឃើញថា យើងតែងតែនាំគ្នានិយាយថាគោរពសច្ចធម៌ ស្រឡាញ់គតិបណ្ឌិត តែពេលខ្លះយើងពុំបានដឹងថាតើសច្ចធម៌ និង គតិបណ្ឌិតនោះ មានអត្ថន័យយ៉ាងណាខ្លះ ជ្រាលជ្រៅយ៉ាងណាខ្លះទេ និង មានប្រយោជន៍សម្រាប់ជីវិត និង សង្គមមនុស្សដូចម្តេចខ្លះ ?

ដើម្បីជាការសាកល្បងរួមវិភាគទានជាគំនិត ក្នុងអត្ថិភាពដែលបានកើតមកជាមនុស្សម្នាក់ ជាខ្មែរម្នាក់ជាម្នាក់ ក្រោយពីពេលបានកើត រស់ គួរណាស់តែបានធ្វើអ្វីជាកុសលបន្សល់ទុកជាអនុស្សា-
-វរីយ៍នៃជីវិតក្រោយពេលស្លាប់ បើមិនបានធ្វើអ្វីជាដុំកំភួន ក៏គួរតែមានអ្វីខ្លះទុកជាមរតកសម្រាប់អ្នកជំនាន់ក្រោយខ្លះផងដែរ ។

# សច្ចធម៌ និង ពុទ្ធិគតិបណ្ឌិត

ពុំមែនទ្រព្យសម្បត្តិ សម្ភារៈ មាសពេជ្រ យសស័ក្តិនោះទេ ដែលធ្វើអោយមនុស្សថ្លៃថ្នូរឬថោកទាប ឬមានតម្លៃទាំងស្រុងនោះ។ គំនិត ស្នាដៃ ប្រកបដោយគុណធម៌ គឺពិតជាលក្ខណៈវិនិច្ឆ័យ និង មានតម្លៃមិនសាបសូន្យ សម្រាប់ជួយទ្រទ្រង់សង្គមជាតិរបស់ខ្លួន ទ្រទ្រង់ទឹកដីខ្យល់អាកាស ដើម្បីជាការតបស្នង ដឹងគុណដល់គុណទឹកដី ដែលបានបង្កលក្ខណៈអោយមនុស្សបានរស់នៅ ស្គាល់រសជាតិនៃជីវិតពិតប្រាកដនោះ ។

សង្ឃឹមថាកូនសៀវភៅនេះ នឹងបានក្លាយជាកល្យាណមិត្ត គំនិតពិតប្រាកដ រួមដំណើរលើវិថីនៃសភាវៈជីវិតជាមួយអស់លោក-អ្នក **ដើម្បីរៀនរស់** និង **រៀនស្លាប់** អោយបានត្រឹមត្រូវល្អប្រសើរ ដោយខំស្វែងរកនូវការកសាងសន្សំកុសល តាមរយៈការសាង រក្សា **សីល សមាធិ បញ្ញា**, និង នៅថ្ងៃមួយនោះ ... បានញញឹមលាជីវិត ដោយសេចក្តីស្មោះសរ ដោយគ្មានវិប្បដិសារី ! ( *មនុស្សគ្រប់រូបសុទ្ធតែមានទីបញ្ចប់របស់ខ្លួនគ្រប់គ្នា* ) ។

ប្រសិនបើកូនសៀភៅនេះ បានរួមផ្តល់នូវគុណប្រយោជន៍ពិតមែននោះ ខ្ញុំសូមឧទ្ទិសនូវកុសលដ៏ថ្លៃថ្លានេះ ជូនប្រជាពលរដ្ឋខ្មែរ និង មាតុភូមិកម្ពុជាដ៏កំសត់ សូមអោយបានក្លាយជាសង្គមវប្បធម៌-សីលធម៌ គុណធម៌ ពិតប្រាកដឡើងវិញកុំបីអាក់ខាន !

**ដោយសេចក្តីមេត្តា និង ការគោរពបំផុត អំពីខ្ញុំ !**

**ព្រហ្ម-មេត្តា**

# ឧទ្ទិសកថា

ខ្ញុំសូមវន្ទាអញ្ជលីឧទ្ទិសនូវឥដ្ឋមនុញ្ញផលកុសល ដែលបានមកពីការប្រមូលគំនិតជាតិ ឆ្លៀតចងក្រងប្រមូលរៀបរៀងសៀវភៅ "**សច្ចធម៌ និង ពុទ្ធិគតិបណ្ឌិត**" នេះ ជាសក្ខីភាពនៃការគោរព ដ៏ជ្រាលជ្រៅ ប្រកបដោយសេចក្ដីកតញ្ញូកតវេទីដ៏ខ្ពង់ខ្ពស់បំផុត ជូនចំពោះព្រលឹងទឹកដីមហានគរខ្មែរ បុព្វវីរបុរសជាតិខ្មែរ បុព្វការីជនអ្នកមានគុណ វិញ្ញាណក្ខន្ធខ្មែរទាំងឡាយ ដែលបានលះបង់បូជាជីវិត ដ៏ អង់អាចក្លាហានដើម្បីការពារជាតិសាសន៍ ភាពស្ថិតស្ថេរ គង់វង្ស រីកចំរើន នៃវប្បធម៌ អរិយធម៌ខ្មែរ... និង ខ្មែរដែលស្លាប់ដោយការរងគ្រោះព្រោះភាពស្លូតត្រង់ គ្រប់សម័យកាល...

សូមព្រលឹងវីរបុព្វបុរសជាតិ ព្រលឹងគុណធម៌ សូមជួយតម្រង់ចិត្តអ្នកដែលមានគំនិត មិច្ឆាទិដ្ឋិ សូមបែរមកសាងភាពសុចរិតនៃគំនិត = "*សម្មាទិដ្ឋិ*" ងាកមកសាងសេចក្ដីមេត្តា ករុណាធម៌ចំពោះសង្គមជាតិ-មាតុភូមិដ៏កំសត់របស់ខ្លួន ដោយការខិតខំកសាងកុសលពិតជូនសង្គមជាតិទុកឱកាសអោយព្រលឹងនៃគុណធម៌បានមកគ្រប់គ្រងថែរក្សា ការពារទឹកដី ព្រៃព្រឹក្សបព្វតា លតាវល្លិ ឈាមជ័រពូជពង្ស វង្សត្រកូល ព្រលឹងជាតិ ព្រលឹងគុណធម៌ អោយបានស្ថិតស្ថេរ គង់វង្ស ថ្កុំថ្កើង រុងរឿង តរៀងទៅជាភិយ្យោភាព !

**ព្រហ្ម-មេត្តា** (ហៅ **ជ័យវរិន្ទ**)

## សច្ចធម៌ និង ពុទ្ធិគតិបណ្ឌិត

---

## ដោយសេចក្ដីគោរព កតញ្ញូកតវេទិតាបំផុត ចំពោះ :

**វិញ្ញាណក្ខន្ធបុព្វការីជន លោក-អ្នក ដ៏មានគុណទាំងអស់ :**

- លោកតាទួត **ម៉ៅ-មាស** និង លោកយាយ **ទេស**
- លោកតា **មាស-វណ្ណ** លោកយាយ **ឯម**
- លោកតា **គុង-អៀប** លោកយាយ **មាស-សន**
- លោកតា **ប៊ី-គួង** លោកយាយ **អ៊ុក-គោ**
- លោកឪពុក **គុង-សំអួន** អ្នកម្ដាយ **ប៊ី-គិមហ៊ន**

ដែលលោកបានខិតខំចិញ្ចឹមបីបាច់ ថែរក្សា អប់រំ ខ្ញុំបាទជាចៅ ជាកូន រហូតដល់បានក្លាយជា**មនុស្សខ្មែរអ្នកជា**ម្នាក់ ដូចសព្វថ្ងៃនេះ សមតាមបំណងប្រាថ្នារបស់អស់លោក-អ្នកមានគុណ !

**ចំពោះព្រះសង្ឃ លោកគ្រូ-អ្នកគ្រូ ជាគ្រូបាធ្យាយទាំងអស់ :**

ដែលបានរួមផ្ដល់ នូវការអប់រំបណ្ដុះនូវពុទ្ធិគ្រប់បែបយ៉ាងដល់រូបខ្ញុំជាសិស្សរបស់លោក ក្នុងគ្រប់វ័យ និង គ្រប់ភូមិសិក្សា ។

**និង ចំពោះអស់លោក-អ្នក សៀវភៅច្បាប់ដែលមានឧបការៈទាំងឡាយ !**

ដែលបានផ្ដល់នូវការឧបត្ថម្ភគ្រប់បែបយ៉ាង ក្នុងការរួមចំណែកផ្ដល់នូវសមានចិត្ត កម្លាំងចិត្តជួយជ្រោមជ្រែងខ្ញុំបាទ !

ការមានតែទ្រព្យសម្បត្តិ មាសប្រាក់ យសស័ក្តិ អំណាច ដោយគ្មានសីលធម៌ និង គុណធម៌ នឹងធ្វើអោយបុគ្គលមានការត្លើតត្លើន មានអំនួត មានជំនោរ ប្រកាន់ខ្លួន លើកកំពស់ខ្លួន មានប្រមាថ (មើលងាយអ្នកដទៃ ) និង ប្រមាទ (មើលងាយខ្លួនឯង ) ពុំអាចទទួលបាននូវការគោរព ស្រឡាញ់ដោយពិតប្រាកដឡើយ ៕

ការមានព្រះធម៌ មានសីលធម៌ មានគុណធម៌ល្អបរិសុទ្ធ ( មេត្តា ករុណា មុទិតា ឧបេក្ខា ) នាំអោយមនុស្សសុភាពរាបសា ទន់ភ្លន់ រឹងប៉ឹង នឹងន រស់នៅសាមញ្ញ ទទួលបាននូវការគោរព ស្រឡាញ់រាប់អាន ពិតប្រាកដ !

ធ្វើអោយគេ **ខ្លាច និង** ធ្វើអោយគេ **គោរព** ពុំមានន័យដូចគ្នាទេ !

ធ្វើអោយគេខ្លាចដោយអំណាចយសស័ក្តិ មាសប្រាក់ ដោយសេចក្តីល្ងង់ខ្លៅ ពុំមែនជាសញ្ញាណនៃគតិបណ្ឌិតឡើយ ហើយក៏ពុំមែនជាប្រការចាំបាច់ដែរ ។

ធ្វើអោយគេគោរព-ស្រឡាញ់ ដោយការមាន**គតិបណ្ឌិត មានភាពសុចរិតនៃគំនិត** មានសេចក្តីបរិសុទ្ធដោយ **សីលធម៌** និង **គុណធម៌** ទើបជាការប្រសើរ និង ចាំបាច់ ។

# មាតិកា


១. គួរពិចារណា !........................................................ ទំព័រ ១២
២. មើល...ជីវិត ! ........................................................ ទំព័រ ១៣
៣. តម្លៃនៃគុណធម៌ ........................................................ ទំព័រ ១៤
៤. កំណាព្យៈ មៀនរស់ !........................................................ ទំព័រ ១៦
៥. កំណាព្យៈ សច្ចធម៌ ........................................................ ទំព័រ ១៧
៦. សច្ចធម៌ជាអ្វី ?........................................................ ទំព័រ ១៨
៧. ត្រៃលក្ខណ៍........................................................ ទំព័រ ២០
៨. ចតុរារិយសច្ចធម៌........................................................ ទំព័រ ២១
៩. អដ្ឋង្គិកមគ្គ........................................................ ទំព័រ ២២
១០. បដិច្ចសមុប្បាទ........................................................ ទំព័រ ២៤
១១. កម្ម_ផល ........................................................ ទំព័រ ២៧
១២. ទុក្ខ ១២ កង........................................................ ទំព័រ ២៨
១៣. បញ្ចក្ខន្ធ ........................................................ ទំព័រ ២៩
១៤. ធាតុបួន : ទឹក ដី ភ្លើង ខ្យល់........................................................ ទំព័រ ៣០
១៥. បឋវីធាតុ ២០........................................................ ទំព័រ ៣០
១៦. អាបោធាតុ ១២ ........................................................ ទំព័រ ៣១
១៧. វាយោធាតុ ៦ ........................................................ ទំព័រ ៣២
១៨. តេជោធាតុ ៤ ........................................................ ទំព័រ ៣៣
១៩. អ្វីទៅជាគតិបណ្ឌិត ? ........................................................ ទំព័រ ៣៤

២០_ ទស្សនៈសម្តេចព្រះសង្ឃរាជ ជួន ណាត ..................... ទំព័រ ៣៦
២១_ពិចារណាពីពាក្យថា "សុំសីល" ............................... ទំព័រ ៣៧
២២_សីលធម៌ ៥ ឬ និច្ចសីល ........................................... ទំព័រ ៣៩
២៣_លោកបាលធម៌ ........................................................ ទំព័រ ៤០
២៤_ កំណាព្យ : គុណធម៌ ................................................ ទំព័រ ៤១
២៥_ត្រៃគុណ .................................................................. ទំព័រ ៤៣
២៦_ និវរណធម៌ ............................................................. ទំព័រ ៤៧
២៧_កាលាមសូត្រ ............................................................ ទំព័រ ៤៨
២៨_គុណធម៌ ៤ ................................................................ ទំព័រ ៤៩
២៩_ អរិយទ្រព្យ ៧ ......................................................... ទំព័រ ៥០
៣០_ សប្បុរិសធម៌ ៧ ......................................................... ទំព័រ ៥១
៣១_ វិជ្ជាប្រាំបីប្រការ........................................................ ទំព័រ ៥២
៣២_សង្ខេបព្រះពុទ្ធឱវាទ ................................................ ទំព័រ ៥៣
៣៣_សុចរិត ៣ យ៉ាង ........................................................ ទំព័រ ៥៤
៣៤_ ទុច្ចរិត ៣ យ៉ាង ....................................................... ទំព័រ ៥៥
៣៥_ កុសលមូល ៣ ............................................................ ទំព័រ ៥៦
៣៦_ អកុសលមូល ៣ ......................................................... ទំព័រ ៥៦
៣៧_ការសិក្សាពីមនុស្ស .................................................. ទំព័រ ៥៧
៣៨_ មេរៀនអំពីកំហុស .................................................... ទំព័រ ៥៧
៣៩_ មនុស្ស ៤ យ៉ាង ........................................................ ទំព័រ ៥៨
៤០_ ចរិតបុគ្គល ៦ យ៉ាង .................................................. ទំព័រ ៥៩

**៤១_ អគតិ ៤** ............................................. ទំព័រ ៥៩
**៤២_ពាក្យដែលគួរពោល** ............................................. ទំព័រ ៦០
**៤៣_ អនុស្សតិ ១០** ............................................. ទំព័រ ៦១
**៤៤_ កម្មដ្ឋាន** ............................................. ទំព័រ ៦២
**៤៥_ ឧបក្កិលេស ១៦** ............................................. ទំព័រ ៦៣
**៤៦_ និព្វានជាអ្វី ?** ............................................. ទំព័រ ៦៤
**៤៧_ ទសបារមី** ............................................. ទំព័រ ៧៦
**៤៨_ មង្គលជីវិត ៣៨ ប្រការ** ............................................. ទំព័រ ៧៨
៤៩_ កំណាព្យ : **ពិចារណាពីជីវិត** ............................................. ទំព័រ ៩០
៥០_ កំណាព្យ : **រៀនស្លាប់** ............................................. ទំព័រ ៩២
**៥១_ បញ្ញើឯកសារពិគ្រោះ** ............................................. ទំព័រ ៩៣
**៥២_អវសានកថា** ............................................. ទំព័រ ៩៨

# គួរពិចារណា !

~ មានទ្រព្យមាសប្រាក់ យសស័ក្តិ អំណាច
បើចិត្តលិចសាច ភ្លេចគុណធម៌ថ្លៃ
មិនស្គាល់សច្ចៈ អវិជ្ជាក្រាស់ក្រៃ
ប្រមាថខែថ្ងៃ អប្រិយអាត្មា ៚

~ ផឹកទឹកសមុទ្រ កាន់ផឹកកាន់ស្រេក
ដូចជាតម្រេក ស្រេកឃ្លានប្រាថ្នា
អវិជ្ជាមិនដឹង ស្រវឹងតណ្ហា
មិនយល់ អនត្តា គិតថាមាន "អញ" ៚

~ ការមានគុណធម៌ លំអជីវិត
យល់គិតត្រឹមត្រូវ រស់នៅសាមញ្ញ
សុភាពថ្លៃថ្នូរ មិនជោរអួតអញ
ស្រឡាញ់សច្ចៈ ខ្ជាក់ចោលមាយា ៚

© ព្រហ្ម~មេត្តា

# មើល...ជីវិត

~ **មើល...ជីវិត** គិត... ឃើញដូចពពក
រសាត់ទៅមក ជ្រកក្នុងវេហាស៍
ដូចជាជីវិត ក្នុងវដ្តសង្សារ
វង្វេងលោកា ថា "**អាត្មា**" ពិត ។

~ អវិជ្ជាតណ្ហា និង ឧបាទាន
នាំចិត្តស្រេកឃ្លាន ទន្ទ្រានជីវិត
រស់រៀនអប់រំ បន្ទុំគំនិត
អប់រំជីវិត ប្រព្រឹត្តសុចរិត ។

~ រស់ស្គាល់សច្ចៈ មិនអវិជ្ជា
សាងសីលសទ្ធា ជាគុណធម៌ពិត
**ស្ងាប់គ្រអូបឈ្មោះ រស់គ្រអូបចិត្ត**
ជីវិតសុចរិត ប្រព្រឹត្តធម៌បួន ។

~ ទីមួយ "**មេត្តា**" "**ករុណា**" ទីពីរ
ទីបីសំភី មូលមីរមាំមួន
"**មុទិតាធម៌**" ស្មោះសរខ្ជាប់ខ្លួន
"**ឧបេក្ខា**" ទីបួន ក្បួនគុណធម៌ខ្មែរ !

# តម្លៃនៃគុណធម៌

នោះកិត្តិយសក្តី នោះភោគសម្បត្តិក្តី នោះកេរ្តិ៍ឈ្មោះក្តី នោះជាការមានចំណេញសំរាប់ផ្ទាល់ខ្លួនក្តី ក៏មិនអាចនាំបុគ្គលដែលមានគុណធម៌ខ្ពស់ មានគតិបណ្ឌិត គោរពសច្ចធម៌ មានព្រលឹងបរិសុទ្ធថ្លៃថ្នូរ អោយប្រព្រឹត្ត អំពើអ្វី ៗ ដែលជាការផ្ទុយនាស់នឹងសតិសម្បជញ្ញៈ គុណធម៌ព្រះធម៌បានឡើយ !

ជីវិតដែលមានឥស្សរភាព មានសេរីភាព គឺជាជីវិតដែលបានប្រយុទ្ធច្បាំងឈ្នះអាត្មាខ្លួនឯង កាច់បំបាក់នូវច្រវាក់ចំណងចំណង់តណ្ហា និង ឧបាទាន !

កាន់តែចង់...កាន់តែប្រាថ្នា, កាន់តែចង់...កាន់តែជោរ, កាន់តែចង់...កាន់តែអួត, កាន់តែចង់...កាន់តែឈឺចាប់, កាន់តែចង់...កាន់តែខ្វះណាស់, កាន់តែចង់...កាន់តែវង្វេង...

បើចង់គ្រប់ ត្រូវទប់ចង់ !

# សច្ចធម៌ និង ពុទ្ធិគតិបណ្ឌិត

**សមត្ថភាព តម្លៃនៃជីវិត និង សេចក្តីថ្លៃថ្នូរ ពិតប្រាកដរបស់មនុស្ស ត្រូវវាស់ដោយ "គុណធម៌" មិនមែនដោយសារទ្រព្យសម្បត្តិមាសប្រាក់ធនធាន ឬយសស័ក្តិដែលមានទាំងស្រុងនោះទេ !**

***In One Word, be a Saint***. **Virtue** is the link of all perfections, the center of all the felicities. The virtue makes a person prudent, discreet, sagacious, cautious, wise, courageous, thoughtful, trustworthy, happy, honored, truthful, and a universal hero. ***Three things*** make a person happy : **Health, Holiness** and **Wisdom**.

***A Person's Capacity and Greatness are to be measured by his Virtue and not by his Fortune !***

**THE ART OF WORLDLY WISDOM**

# រៀនរស់...

~ កើតមកជាមនុស្ស **រៀនរស់...** ព្រោះអ្វី ?
ទឹកដី ភ្លើងខ្យល់ បំណុលជីវិត
រស់រៀន...រៀនរស់ ខ្ពង់ខ្ពស់គំនិត
រស់រៀន ប្រព្រឹត្ត គិតគុណទឹកដី ។

~ បើរស់មិនដឹង មិនប្រឹងសំអាត
រស់ក្នុងប្រមាទ ខាតបង់ខែថ្ងៃ
បើរស់អវិជ្ជា ពាលាអប្រិយ
រស់គ្មានតម្លៃ អប្រិយអាត្មា ។

~ មើលឃើញសច្ចៈ ត្រៃលក្ខណ៍ រូបំ
ជីវិត **អនិច្ចំ** **ទុក្ខំ អនត្តា**
កុំរស់វែកពុន ទម្ងន់តណ្ហា
**បណ្តុះបញ្ញា** **រក្សាគុណធម៌** !

© **ជ័យវរិន្ទ**

# សច្ចធម៌

~ កើតមកជាមនុស្ស  រស់មានជីវិត
គួរដឹងការពិត  គិតដឹងហេតុ-ផល
អវិជ្ជាដើមចម  នាំចិត្តអកុសល
តណ្ហាបំពុល  យល់ខុសបំពាន ។

~ បើស្គាល់សច្ចៈ  ភ្ញាក់រឭកត្រូវ
ព្រះធម៌ជាផ្លូវ  នាំទៅនិព្វាន
សីលប្រាំចាំជាប់  អប់រំសីលទាន
ព្រះធម៌ជាយាន  ស្ពានភ្ជាប់និស្ស័យ ។

~ ព្រះធម៌វិន័យ  ខន្តីរស់នៅ
គុណធម៌ជ្រាលជ្រៅ  ផ្លូវកុសលបី
**ស្គាល់សច្ចធម៌**  ត្រាច់ចរយប់ថ្ងៃ
ដូចមានរស្មី  បំភ្លឺជីវិត ។

© **ព្រហ្ម មេត្តា**

# សច្ចធម៌ជាអ្វី?

**សច្ចធម៌** គឺជាសភាវៈពិត ដំណើរពិតនៃធម្មជាតិ ដែលមិនចំណុះទៅនឹងចំណង់ ចំណូលចិត្តបុគ្គលណា ស្ថានភាពណា កាលៈទេសៈណា អានុភាពណា ឬ អំណាចបុគ្គលណាម្នាក់ឡើយ...

ការស្គាល់ យល់ ដឹងច្បាស់នូវសច្ចធម៌ នឹងនាំអោយយើងរស់នៅដោយត្រឹមត្រូវ ប្រកបដោយគតិបណ្ឌិត មានគំនិតគិតយល់ឃើញត្រឹមត្រូវក្នុងផ្លូវហេតុ_ផល មិនវង្វេង មិនស្រវឹង មិនជោរអួតអាងនឹងជីវិត នឹងភាពមាយាលាក់ពុតនៃលោកិយនេះ ។

ការស្គាល់ យល់ ដឹងច្បាស់នូវសច្ចធម៌ នឹងនាំអោយយើងមានសតិ_សម្បជញ្ញៈ មនសិការគ្រប់គ្រាន់ ដើម្បីទទួលស្គាល់នូវការពិតនៃជីវិត ហើយរៀនរស់ និង រៀនស្លាប់ បានដោយល្អប្រពៃ ។

# តើអ្វីខ្លះទៅជា សច្ចធម៌?

# ឆេះដាសច្ចធម៌!

➢ **ជាតិ ជរា ព្យាធិ មរណៈ**

**កើត ចាស់ ឈឺ ស្លាប់ !**

| | | |
|---|---|---|
| កើត | ⇔ | ស្លាប់, |
| ស្រឡាញ់ | ⇔ | ស្អប់, |
| សុខ | ⇔ | ទុក្ខ, |
| ចូល | ⇔ | ចេញ, |
| ជួប | ⇔ | ព្រាត់, |
| បាន | ⇔ | បាត់, |
| ផ្ដើម | ⇔ | បញ្ចប់ ... |

# ➢ ត្រៃលក្ខណ៍

## ( លក្ខណៈពិត ៣ យ៉ាង នៃជីវិត )

• **អនិច្ចំ** : សភាពជារបស់មិនទៀងទាត់ មិនស្ថិតស្ថេរ មិនប្រាកដប្រជា **(Impermanence).**

• **ទុក្ខំ** : សភាពជាទុក្ខ មានរូប មានរោគ មានរឿង មានទុក្ខឈឺចាប់... **(Suffering).** មានជីវិត គឺមានបញ្ហា **(*Tout est problème*).**

• **អនត្តា** : សភាពជារបស់មិនមែនខ្លួន មិនមានអញ ... **(Non-Self, Emptyness).**

# ➢ ចតុរារិយសច្ចៈ

## ( ការពិតដ៏ប្រសើរទាំង ៤ យ៉ាង )

- **ទុក្ខសច្ចៈ** : ជីវិតប្រកបដោយសេចក្ដីទុក្ខមែនពិត ឥតចៀសវាងបាន, **ជីវិត គឺជាបញ្ហា,**
- **សមុទយសច្ចៈ** : សេចក្ដីទុក្ខកើតមាន ព្រោះមានហេតុ នាំអោយមានទុក្ខ ( **ខន្ធ ៥**, **អវិជ្ជា តណ្ហា ឧបាទាន** ) ។
- **និរោធសច្ចៈ** : ទុក្ខអាចរំលត់បាន ដោយស្គាល់ហេតុ គឺការរំលត់នូវទុក្ខ ទាំង ១២ កង,
- **មគ្គសច្ចៈ** : ផ្លូវ ឬមធ្យោបាយចេញចាកទុក្ខ ,

( មាគ៌ានិព្វាន សំដៅដល់ អដ្ឋង្គិកមគ្គ ឬ មជ្ឈិមប្បដិបទា )។

# សច្ចធម៌ និង ពុទ្ធិគតិបណ្ឌិត

## ➤ អដ្ឋង្គិកមគ្គ ឬ មជ្ឈិមប្បដិបទា :

**បញ្ញា**

- **សម្មាទិដ្ឋិ** : ការយល់ឃើញច្បាស់នូវសច្ចធម៌ តាមផ្លូវបញ្ញា,
- **សម្មាសង្កប្បៈ** : ការត្រិះរិះគិតឃើញត្រឹមត្រូវ តាមផ្លូវវិចារណញ្ញាណ មានហេតុ-ផល,

**សីល**

- **សម្មាវាចា** : វាចាប្រពៃ (វៀរចាកវចីទុច្ចរិតទាំង ៤),
- **សម្មាកម្មន្តៈ** : ការងារប្រពៃ (វៀរចាកការប្រព្រឹត្តខុសដោយកាយ ៣ យ៉ាង),
- **សម្មាអាជីវៈ** : ចិញ្ចឹមជីវិតដោយប្រពៃ (វៀរចាកការប្រព្រឹត្តខុសក្នុងការចិញ្ចឹមជីវិត),

**សមាធិ**

- **សម្មាវាយាមៈ** សេចក្តីព្យាយាមត្រឹមត្រូវក្នុងផ្លូវជាកុសល ជាគុណប្រយោជន៍ ដោយគុណធម៌ជ្រាលជ្រៅ,
- **សម្មាសតិ** : សេចក្តីភ្ញាក់រលឹកត្រឹមត្រូវ (គឺរលឹកក្នុងសតិប្បដ្ឋាន ៤),
- **សម្មាសមាធិ** : ការប្រមូលផ្តុំអារម្មណ៍អោយត្រជាក់ស្ងប់ ថ្លា តាមគន្លងនៃធម៌ឧបេក្ខា ។

## សច្ចធម៌ និង ពុទ្ធិគតិបណ្ឌិត

# មជ្ឈិមបដិបទា

## ឬ អដ្ឋង្គិកមគ្គ

## ចង្កូតព្រះធម៌សម្រាប់បើកបរនាវាជីវិត
## តម្រង់ទិសឆ្ពោះទៅកាន់និព្វាន




ប្រមូលរៀបរៀង ដោយ ព្រហ្ម-មេត្តា (ហៅ ជយទរិទ្ធ)

## ➢ បដិច្ចសមុប្បាទធម៌

### ឬ ធម្មភាពនៃទំនាក់ទំនងរវាង ហេតុ និង ផល :

- **អវិជ្ជា** : ការមិនដឹង មិនស្គាល់សច្ចធម៌ មិនស្គាល់ត្រៃលក្ខណ៍ មិនស្គាល់ហេតុ_ផល,
- **សង្ខារ** : ការតាក់តែងឡើងនូវ "កម្ម" ទាំងឡាយ,
- **វិញ្ញាណ** : ការដឹងនូវអារម្មណ៍ទាំងឡាយ,
- **នាម_រូប** : សភាវនាម និង សភាវរូប (**ខន្ធ ៥** ឬ **បញ្ចក្ខន្ធ** )
- **សឡាយតនៈ** ទ្វារអារម្មណ៍ទាំង ៦ (ចក្ខុ សោតៈ ឃានៈ ជីវ្ហា កាយ និង មនោវិញ្ញាណ ),
- **ផស្សៈ** : ការប៉ះទង្គិចនៃសឡាយតនៈនឹងភពខាងក្រៅ,
- **វេទនា** : ការទទួលសោយនូវអារម្មណ៍ (ទំនួលអារម្មណ៍)
- **តណ្ហា** : ការត្រេកត្រអាលស្រេកឃ្លានមិនស្កប់ស្កល់
- **ឧបាទាន** : ការជាប់ជំពាក់ចិត្តនឹងអារម្មណ៍
- **ភវៈ** : ទ្រនើរធ្មើរធ្នាក់ទាក់អារម្មណ៍ (ការទើរជាប់ )
- **ជាតិ** : កំណកំណើតនៃអត្ថិភាពទាំងឡាយ
- **ទុក្ខ ទោមនស្ស ជរា ព្យាធិ មរណៈ** សេចក្តីទុក្ខទោមនស្ស ចាស់ ឈឺ ស្លាប់ វិនាសបាត់បង់ទៅវិញ ។

# បដិច្ចសមុប្បាទធម៌

## ទំនាក់ទំនងរវាង ហេតុ និង ផល



# ចំណោទកម្ម និង ផល



កិលេស Defilement
១
២
កម្ម Action
៣
វិបាក Result
តណ្ហា
អវិជ្ជា
សង្ខារ
កម្ម
ភវៈ

## ➢ កម្ម~ផល :

- **កម្ម** : គឺជាសំណុំនៃអំពើ ការធ្វើ ការប្រព្រឹត្ត ទាំងឡាយរបស់បុគ្គល ។
- **ផល** : លទ្ធផលដែលជាប្រតិកម្ម របស់ **កម្ម** នោះ,

បុគ្គលសាង **កម្ម** យ៉ាងណា រមែងទទួល **ផល** យ៉ាងនោះ ។

**កម្ម** និង **ផល** ពុំមែនជាទ្រឹស្តីខ្វះហេតុ-ផល ដូចដែលអ្នកខ្លះបានគិតតាមទស្សនៈមិច្ឆាទិដ្ឋិផ្ទាល់ខ្លួននោះទេ ។ តម្លៃនៃព្រះពុទ្ធឱវាទក្នុងទស្សនៈហេតុ-ផលនេះ គឺថា អ្នកណាសាងកម្មយ៉ាងណា អ្នកនោះនឹងទទួលបាននូវផលបែបនោះ ហើយម្យ៉ាងទៀតក៏គ្មានអ្នកដទៃមកទទួលផលជំនួសអ្នកប្រព្រឹត្តបានឡើយ ។

"**កម្ម ស**" ទទួល " **ផល ស**",

"**កម្មខ្មៅ**" ទទួល "**ផលខ្មៅ**"

"**កម្ម កុសល**" ទទួល " **ផល កុសល**",

"**កម្ម អកុសល**" ទទួល "**ផល អកុសល**" ...

## ➤ ទុក្ខទាំង ១២ កង :

១. **ជាតិទុក្ខ** : ទុក្ខព្រោះមានកំណើត ។

២. **ជរាទុក្ខ** : ទុក្ខព្រោះសេចក្ដីចាស់ជរា គ្រាំគ្រា ។

៣. **ព្យាធិទុក្ខ** : ទុក្ខព្រោះមានជំងឺរោគាបៀតបៀន ។

៤. **មរណទុក្ខ** : ទុក្ខព្រោះត្រូវជួបស្លាប់ដោយចៀសពុំរួច ។

៥. **សោកទុក្ខ** : ទុក្ខព្រោះសេចក្ដីសោកសៅ ស្ដាយស្រណោះ ។

៦. **បរិទេវទុក្ខ** : ទុក្ខព្រោះព្រួយញាំញី រ៉ាំរ៉ៃ រីងរៃ...

៧. **ទុក្ខទុក្ខ** : ទុក្ខហើយទុក្ខទៀត ទុក្ខត្រួតគរលើទុក្ខ ។

៨. **ទោមនស្សទុក្ខ** : ទុក្ខព្រោះការទើសចិត្ត ទើសអារម្មណ៍ ។

៩. **ឧបាយាសទុក្ខ** : ទុក្ខព្រោះការបែកឃ្លាត ព្រាត់ប្រាសគ្នា ។

១០. **អប្បិយេហិ សម្បយោគទុក្ខ** : ទុក្ខព្រោះជួបនឹងវត្ថុ បុគ្គល ឬសភាវៈ មិនជាទីពេញចិត្ត ។

១១. **បិយេហិ វិប្បយោគទុក្ខ** : ទុក្ខព្រោះព្រាត់បាត់ វត្ថុ បុគ្គល ឬសភាវៈជាទីគាប់ចិត្ត ។

១២. **យម្បិច្ឆំ ន លភតិ តម្បិទុក្ខ** ទុក្ខព្រោះប្រាថ្នាចង់បានអ្វី ដែលមិនបានស្របតាមបំណង ។

## ➢ បញ្ចក្ខន្ធ ឬ ខន្ធ ៥ :

**កាយ** និង **ចិត្ត** នៃយើងទាំងរាល់គ្នានេះ ចែកចេញជា **៥** កង ហៅថា ខន្ធ ៥ គឺ : រូប វេទនា សញ្ញា សង្ខារ និង វិញ្ញាណ ។

១. **ធាតុ ៤** គឺ : ទឹក ដី ភ្លើង ខ្យល់ ប្រជុំគ្នាតាក់តែងជារាងកាយ ហៅថា រូប ។

២. ការកំណត់ដឹងនូវអារម្មណ៍ជាសុខ ឬជាទុក្ខ ឬជាឧបេក្ខា (មិនសុខ មិនទុក្ខ) ហៅថា វេទនា ។

៣. សេចក្តីកត់សំគាល់ដឹងចាំបាន គឺ ***រូប សម្លេង ក្លិន រស ផោដ្ឋព្វៈ*** អារម្មណ៍ទាំងនេះហៅថា សញ្ញា ។

៤. ចេតសិកធម៌ គឺអារម្មណ៍ដែលកើតរលត់ជាមួយនឹងចិត្ត ទាំងកុសល ទាំងអកុសល ទាំងអព្យាក្រឹត ហៅថា សង្ខារ ។

៥. សេចក្តីដឹងអារម្មណ៍ ក្នុងវេលាដែលអាយតនៈខាងក្រៅ មកប៉ះទង្គិចអាយតនៈខាងក្នុងហៅថា វិញ្ញាណ ។ ដូចជា "***រូប***" រត់ប៉ះនឹង**ឥន្ទ្រិយភ្នែក** បង្កើតបានជាចក្ខុវិញ្ញាណជាដើម...

**ខន្ធ ៥** នេះ អាចហៅម្យ៉ាងទៀតថា នាមរូប ។ ***វេទនា សញ្ញា សង្ខារ*** និង ***វិញ្ញាណ*** ហៅថា នាមធម៌ ព្រោះពុំមានរូបជាក់ស្តែង មានត្រឹមតែឈ្មោះហៅប៉ុណ្ណោះ ។ ឯសភាវៈ ***រូប*** ដែលអាចមើលឃើញ ប៉ះពាល់ត្រូវ ហៅថា រូបធម៌ ។

# ➢ ធាតុ ៤ សម្រាប់ទ្រទ្រង់
# និង រំលាយនូវអត្ថិភាព នៃរូប នៃជីវិត
# ដី ទឹក ខ្យល់ ភ្លើង

➪ **បឋវីធាតុ** គឺធាតុរឹង ឬធាតុទន់ទាំងឡាយនៅក្នុងខ្លួនមនុស្សយើងដែលអាច រលត់ រលេះ រលួយ រលាយ ក្លាយទៅជាធាតុ **ដី** បាន, មាន **២០** យ៉ាងគឺ :

| | | | |
|---|---|---|---|
| ១. | **កេសា** | : | សក់ទាំងឡាយ |
| ២. | **លោមា** | : | រោមទាំងឡាយ |
| ៣. | **នខា** | : | ក្រចកទាំងឡាយ |
| ៤. | **ទន្តា** | : | ធ្មេញទាំងឡាយ |
| ៥. | **តចោ** | : | ស្បែក |
| ៦. | **មំសំ** | : | សាច់ |
| ៧. | **នហារូ** | : | សរសៃទាំងឡាយ |
| ៨. | **អដ្ឋិ** | : | ឆ្អឹងទាំងឡាយ |
| ៩. | **អដ្ឋិមិញ្ជំ** | : | ខួរក្នុងឆ្អឹង |
| ១០. | **វក្កំ** | : | ទាច (តម្រងទឹកមូត្រ ឬប្លោក) |
| ១១. | **ហទយំ** | : | បេះដូង |

១២. យកនំ : ថ្លើម

១៣. កិលោមកំ : វាវ

១៤. បិហកំ : ក្រពះ

១៥. បប្ផាសំ : សួត

១៦. អន្តំ : ពោះវៀនធំ

១៧. អន្តគុណំ : ពោះវៀនតូច

១៨. ឧទរិយំ : អាហារថ្មី

១៩. ករីសំ : អាហារចាស់

២០. មត្ថកេមត្ថលុង្គំ : ខួរក្នុងក្បាល ។

➪ **អាបោធាតុ** គឺជាធាតុរាវ ពោលគឺធាតុ **ទឹក** នៅក្នុងខ្លួនមនុស្សយើង គឺវត្ថុដែលអាចរលាយក្លាយទៅជាទឹកវិញមាន ១២ យ៉ាង គឺ :

១. បិត្តំ : ទឹកប្រមាត់

២. សេម្ហំ : ស្លេស្ម

៣. បុព្វោ : ខ្ទុះ

៤. លោហិតំ : ឈាម

៥. សេទោ : ញើស

| | | | |
|---|---|---|---|
| ៦. | មេទោ | ៖ | ខ្លាញ់ខាប់ |
| ៧. | អស្សុ | ៖ | ទឹកភ្នែក |
| ៨. | វសា | ៖ | ខ្លាញ់រាវ |
| ៩. | ខេឡោ | ៖ | ទឹកមាត់ |
| ១០. | សិង្ឃាណិកា | ៖ | ទឹកសម្បោរ |
| ១១. | លសិកា | ៖ | ទឹករំអិល |
| ១២. | មុត្តំ | ៖ | ទឹកមូត្រ |

## ➪ វាយោធាតុ គឺធាតុ ខ្យល់ ៦ ៖

| | | | |
|---|---|---|---|
| ១. | ឧទ្ធង្គមវាត | ៖ | ខ្យល់បក់ពីចុងជើងឡើងទៅក្បាល ។ |
| ២. | អធោគមវាត | ៖ | ខ្យល់បក់ពីក្បាលចុះទៅចុងជើង ។ |
| ៣. | កុច្ឆិសយវាត | ៖ | ខ្យល់បក់វិលវល់ក្នុងពោះ ។ |
| ៤. | កោដ្ឋាសយវាត | ៖ | ខ្យល់បញ្ជូនចុះឡើងក្នុងពោះវៀន ។ |
| ៥. | អង្គមង្គានុសារិវាត | ៖ | ខ្យល់បក់ចុះឡើងសព្វសព៌ាង្គកាយ។ |
| ៦. | អស្សាស បស្សាសវាត | ៖ | ខ្យល់ដកដង្ហើមចេញចូល ។ |

## តេជោធាតុ គឺធាតុសម្រាប់កំដៅសរីរៈឱ្យក្តៅ

ឬធាតុ ភ្លើង ៤ :

១. **សន្តប្បគ្គិ** : ភ្លើងធាតុដែលញ៉ាំងកាយឱ្យក្តៅជាប្រក្រតី ។

២. **ជីរណគ្គិ** : ភ្លើងធាតុដែលញ៉ាំងកាយឱ្យជរាទ្រុឌទ្រោម ។

៣. **បរិឌយ្ហគ្គិ** : ភ្លើងធាតុដែលញ៉ាំងកាយឱ្យក្តៅរោលរាល ។

៤. **បរិណាមគ្គិ** : ភ្លើងធាតុដែលសម្រាប់កិនរំលាយអាហារ ។

# អ្វីទៅជាគតិបណ្ឌិត?

**គតិបណ្ឌិត** គឺជាភាពភ្លឺស្វាង ឈ្លាសវៃនៃគំនិត សតិ-បញ្ញា វិចារណញ្ញាណ មានសុភនិច្ឆ័យ មើលឃើញ ស្គាល់ យល់ ដឹង វិភាគរាល់បញ្ហា ដោយឈរលើមូលដ្ឋាននៃទស្សនៈគោលការណ៍ **ហេតុ-ផល** គ្រប់ជ្រុងជ្រោយ មិនបំផ្លើស មិនបំភ្លៃ មិនវិនិច្ឆ័យព្រហើនតាមអស្មិមានះបុគ្គល មិនលំអៀងតាមអគតិ មិច្ឆាទិដ្ឋិ អវិជ្ជា តណ្ហានិយម យល់ចង្អៀតចង្អល់ឡើយ ។

**គតិបណ្ឌិត** នាំអោយមានចិត្តស្មោះសរ រក្សាខ្ជាប់ខ្ជួននូវគុណធម៌ កុសលធម៌ ស្គាល់គុណ-ទោស ខុស-ត្រូវ ខ្មៅ-ស ល្អ-អាក្រក់ ។ **គតិបណ្ឌិត** នាំអោយមាន **ភាពសុចរិតនៃគំនិត** ។

**ការមានគតិបណ្ឌិត** នឹងនាំអោយមនុស្សរស់នៅដោយសាមញ្ញ សុភាពរាបសា មិនអួតអាង មិនជោរស្រវឹងវង្វេង នឹងលោកធម៌ទាំង ៨ប្រការ ។

**ការមានគតិបណ្ឌិត** នឹងនាំអោយមនុស្ស គោរពសច្ចធម៌ មានសេរីភាព មានឥស្សរភាព ហើយមិនបណ្តោយអោយជីវិតរស់រិលវល់ស្ថិតក្រោមឥទ្ធិពលនៃតណ្ហាថោកទាបឡើយ ។

## អត្តា ហវេ ជិតំ សេយ្យោ
## ឈ្នះខ្លួនឯង ប្រសើរជាងឈ្នះអ្វីទាំងអស់ ។

នៅលើសមរភូមិប្រយុទ្ធតតាំងជាមួយខ្មាំងសត្រូវ គេអាចជួយច្បាំងប្រយុទ្ធនឹងខ្មាំងសត្រូវជំនួសគ្នាបាន តែក្នុងសមរភូមិប្រយុទ្ធជាមួយ "**អត្តៈ អាត្មាខ្លួនឯង**" គេមិនអាចប្រយុទ្ធជំនួសគ្នាបានឡើយ គឺមានតែខ្លួនយើងផ្ទាល់ប៉ុណ្ណោះ ដែលត្រូវប្រើព្រះខ័នឫទ្ធិ "**សីល សមាធិ បញ្ញា**" បង្ក្រាបកិលេសតណ្ហា ច្បាំងនឹងខ្មាំងអវិជ្ជា ដែលលួចពួនសំងំ បន្ទំ បង្កប់ខ្លួននៅក្នុងទីងងឹតកន្លៀតកៀនកោះ នៃចិត្តរបស់យើងម្នាក់ ៗ ។

**គេអាចច្បាំងឈ្នះលើទ័ពរបស់ភាគីបដិបក្ខរាប់រយ ពាន់ម៉ឺនសែននាក់លើសមរភូមិសង្គ្រាមបាន...តែជោគជ័យដ៏ប្រសើរជាងនេះ ហើយកាត់ថ្លៃមិនបាននោះ នោះគឺសេចក្តីក្លាហាន ហ៊ានតតាំងច្បាំងប្រយុទ្ធយកសព្វជ័យលើអាត្មាខ្លួនឯងតែម្តង** (តតាំងច្បាំងនឹងខ្មាំង **អវិជ្ជា តណ្ហា ឧបាទាន** )។

# សច្ចធម៌ និង ពុទ្ធិគតិបណ្ឌិត

## ទស្សនៈមួយចំនួន

របស់សម្ដេចព្រះសង្ឃរាជ **ជួន~ណាត**

~ ជីវិតរាល់រូបតិចតួចណាស់ ប៉ុន្តែយើងត្រូវប្រឹងរៀន ប្រឹងរក ប្រឹងគិត ប្រឹងប្រព្រឹត្តល្អ ហាក់ដូចជាយើងនឹងមានជីវិតរស់នៅរាប់ពាន់ឆ្នាំ !

~ **ស័ក្តិពុំស្មើយស នារអ្នកខ្ពង់ខ្ពស់ ពុំស្មើចិត្តជា !**

~ អ្នកប្រាជ្ញ សូម្បីរាងកាយទ្រុឌទ្រោមជិតដល់នូវមរណភាពហើយក៏ដោយ ក៏លោកមិនព្រមបោះបង់ការងារដ៏ប្រសើររបស់លោកឡើយ ព្រោះលោកយល់ច្បាស់ថា **សេចក្ដីស្លាប់** ជាធម៌ទៀង ។

~ ការដែលគេឱ្យយើងស៊ី មកតែគេចង់ស៊ីពីយើង ...

~ ការដែលគេមកសុំសន្លឹកឆ្នោតពីយើង គេលុតជង្គង់ដល់ធរណី ព្រោះតែគេចង់ស៊ីថ្លើមយើង ដល់គេបានសន្លឹកឆ្នោតហើយ គេធាក់ធរណី បោលលែងមកក្បែរយើងទៀត តើយើងត្រូវធ្វើដូចម្ដេចហ្ន៎ ឱ្យបានដូចបំណង ?

(ស្រង់ចាក ទស្សនៈសម្ដេចព្រះសង្ឃរាជ **ជួន~ណាត** )

# ត្រូវពិចារណាពីពាក្យថា ... ទៅសុំសីល !?!

## អ្វីទៅដែលហៅថា "សីល" ?

**សីល** គឺជាការសិក្សាអប់រំ ហ្វឹកហ្វឺន ហាត់ពត់ លត់ដំកិរិយា ចរិយា មារយាទ កាយ វាចា ចិត្ត របស់ខ្លួនយើងម្នាក់ ៗ អោយមានរបៀបរៀបរយ មានសីលធម៌ មានគុណធម៌ល្អប្រសើរត្រឹមត្រូវវៀរចាកអំពើអកុសលទាំងឡាយដែលជាកិលេសតណ្ហា ទាំងដោយកាយ វាចា ចិត្ត ។

ពាក្យ "**សុំ**" ជាគូគ្នានឹងពាក្យ "**អោយ**" មានន័យថា មានម្នាក់ជាអ្នកអោយ ម្នាក់ទៀតជាអ្នកទទួលយក ដូចជាការសុំបាយសុំទឹក សុំប្រាក់កាសគ្នាជាដើម... ឯ **សីល** ពុំមែនជាវត្ថុសម្រាប់ "**សុំ**"សម្រាប់"**អោយ**"គ្នាបានឡើយ គឺជាការខិតខំកសាងធ្វើប្រព្រឹត្តប្រតិបត្តិ រក្សា ប្រយុទ្ធច្បាំងនឹងខ្មាំងកិលេសក្នុងអាត្មាខ្លួនឯងរៀង១ខ្លួន ជារឿយ១ ។ ដូចនេះ **ការរក្សាសីល** ឬ **សាងសីល** ពុំមែនជាការសុំពីគ្នា ចែករំលែកគ្នាតាមមនោសញ្ចេតនាបានឡើយ ។ អ្នកអោយទោះជាមានសទ្ធាចង់អោយ ក៏គ្មានវិធីណាអោយគ្នាកើតឡើយ គ្រាន់

តែមានលទ្ធភាពប្រាប់ពីវិធីស្វែងរកតែប៉ុណ្ណោះ ។ អ្នកទទួល បើមិនប្រឹងកសាងធ្វើដោយខ្លួនឯងទេ ក៏មិនដឹងជាទទួលតាមវិធីណាបានឡើយ ។ ការគ្រាន់តែសូត្រថាតាម នូវសិក្ខាបទទាំងឡាយ ពុំមែនមានន័យគ្រប់គ្រាន់ថាបានសាង"**សីល**"នោះទេ ។ បើមិនយល់ន័យនៃសិក្ខាបទទាំងឡាយ ហើយចេះតែសូត្រថាតាមគេ ទាំងមិនយល់មិនដឹងថាអ្វីជា "**សីល**" ផងនោះ ហើយខ្វះការប្រតិបត្តិជាក់ស្តែងក៏ពុំមានន័យអ្វីទាល់តែសោះ សម្រាប់ការដុសខាត់ ចិត្តគំនិត អោយចេញចាកផុតពីភាពអវិជ្ជា ដែលជាប្រភពនៃអកុសលកម្មទាំងឡាយនោះ។

ដូចនេះ "**សីល**" **គឺពុំមែនជាការសុំនោះទេ** ។ **សីល** គឺជាការយល់ដឹង ហើយប្រព្រឹត្ត សាង ធ្វើ រក្សា ប្រតិបត្តិជាប្រចាំ ដើម្បីដុសខាត់ សំអាត អោយបានល្អបរិសុទ្ធ ។ ដូចជាផ្ទះ ឬទីលំនៅស្ថានដែលបានបើកទ្វារបង្អួច ដើម្បីអោយមានពន្លឺ ខ្យល់អាកាសចេញចូលបានល្អនោះ ក៏រមែងមានទាំងល្អងធូលីហុយដោយទៅជាមួយនឹងពន្លឺខ្យល់អាកាសផងដែរ ។

សួរថាតើត្រូវធ្វើដូចម្តេច ដើម្បីអោយផ្ទះរបស់យើងមានទាំងពន្លឺ មានខ្យល់អាកាសចេញចូលបានផង ទាំងអោយបានស្អាតល្អគ្មានការប្រឡាក់ល្អងធូលីផង ? យ៉ាងណាមិញ "**កាយ វាចា ចិត្ត**" របស់យើងក៏យ៉ាងនោះដែរ ។

ក្នុងករណីនេះ វត្ថុមាននៃ "**សីល**" នេះឯងដែលមានតួនាទីដូចជា "**ទឹកដ៏បរិសុទ្ធ**" សម្រាប់រម្ងាប់សម្រេក និង ដុសលាង ជម្រះសំអាត កាយ វាចា ចិត្ត របស់យើងនោះឯង ។

## ➤ សីល ៥ ឬ បញ្ចសីល ឬ និច្ចសីល

**សីលធម៌_គុណធម៌ ៥ ប្រការ** ដែលបុគ្គលទាំងឡាយ
គួរតែត្រូវគោរព ប្រតិបត្តិ រក្សា ជាប្រចាំ

១- **បាណាតិបាតា វេរមណី...** វៀរចាកកិរិយាការបៀតបៀន ( **ប្រមាថ បំផ្លាញ** ) ដល់ជីវិតមនុស្ស_សត្វទាំងឡាយ ។

២- **អទិន្នាទានា វេរមណី...** វៀរចាកកិរិយាកាន់យកនូវវត្ថុទាំងឡាយណាដែលគេមិនបានឱ្យដោយកាយ ឬវាចា ។

៣- **កាមេសុ មិច្ឆាចារា វេរមណី...** វៀរចាកកិរិយាការប្រព្រឹត្តខុសក្នុងកាម ( *ប្រព្រឹត្តខុសក្នុងកាម ដោយការសេពមេថុននឹងស្ត្រី ២០ ពួក* ) ទាំងឡាយ ។

៤- **មុសាវាទា វេរមណី...** វៀរចាកកិរិយាពោលពាក្យមិនពិត កុហក ភូតភរ បោកប្រាស់ ។

៥- **សុរាមេរយ មជ្ជប្បមាទដ្ឋានា វេរមណី...** វៀរចាកកិរិយានូវហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹក ឬប្រកបនូវគ្រឿងស្រវឹង គឺសុរា និង មេរ័យជាដើម...

## ➢ <u>លោកបាលធម៌</u> ( ធម៌រក្សាលោក ) ៈ

- **សតិ** : សេចក្ដីភ្ញាក់រឭកចាំជានិច្ច
- **សម្បជញ្ញៈ** : សេចក្ដីដឹងខ្លួនជានិច្ច

- **ហិរិ** : អៀនខ្មាស ខ្ពើមរអើមអំពើបាប

*ដូចជាអារម្មណ៍នៅពេលឃើញលាមកជាដើម...*

- **ឱត្តប្បៈ** : ខ្លាចបាប មិនហ៊ានប្រព្រឹត្តបាប

*ដូចជាការដឹងថាភ្លើងក្ដៅ កាន់ទៅនាំអោយរលាកជាដើម...*

# ស្រែគុណ

~ **ស្គាល់គ្រែគុណ** នរជននោះ ឈ្មោះបណ្ឌិត
ព្រោះគំនិត គិតឃើញត្រូវ ផ្លូវកុសល
**មានគុណធម៌** ប្រសើរក្រៃ គ្មានអ្វីដល់
ស្គាល់ហេតុ-ផល យល់ដឹងច្បាស់ **ព្រះគុណបី** ។

~ កើតមកបានរស់ ព្រោះ**គុណឪម៉ែ**
លោកថ្នាក់ថ្នមថៃ ចិត្តស្នេហ៍ប្រណី
ធំឡើងទៅរៀន មានវិជ្ជាល្បី
**គុណគ្រូប្រុសស្រី** គួរលៃគោរព ។

~ **មីងមាជូនតា** **បុព្វការីជន**
ជួយប្រឹងរែកពុន ចាកខ្មៅឧបទ្រព
គុណថ្លៃទាំងបី ប្រពៃដូចម្លប់
**ត្រជាក់ថ្ងៃយប់** **គឺម្លប់ព្រះធម៌** !

© **ព្រហ្ម មេត្តា**

# សច្ចធម៌ និង ពុទ្ធិគតិបណ្ឌិត

- កើតមកជាមនុស្ស រស់មានជីវិត
**មានគតិបណ្ឌិត** ទើបគិតត្រឹមត្រូវ
**រស់ច្បាំងអាត្មា** តណ្ហានាំខ្លៅ
**រស់_ស្លាប់ត្រឹមត្រូវ** តាមផ្លូវមជ្ឈិមា !

- បណ្ដុះ **មេត្តា** **ឧបេក្ខា ខ្ពង់ខ្ពស់**
រស់រៀន_រៀនរស់ ឈ្មោះជាអ្នកជា
មិនធ្វើទាសា តណ្ហាមាយា
សាងសីលភាវនា មាគ៌ាព្រះធម៌ !

**ព្រហ្ម_មេត្តា** ហៅ **ជ័យទរិន្ទ**

# គតិបណ្ឌិត

## ➢ ត្រៃគុណ គឺ ព្រះគុណទាំងបី

### ៙ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ

~ **ព្រះពុទ្ធ** គឺជាអរិយបុគ្គលដែលប្រសើរបំផុតមានព្រះគុណ-សម្បត្តិល្អបរិសុទ្ធ មានព្រះទ័យប្រកបដោយ **បញ្ញាគុណ វិសុទ្ធិគុណ** និង **ករុណាគុណ** និង ដែលបានត្រាស់ដឹងរកឃើញនូវសច្ចធម៌ សម្មាសម្ពោធិញ្ញាណ ដើម្បីអប់រំបំភ្លឺមនុស្សជាតិអោយប្រតិបត្តិល្អ ដោយកាយ វាចា ចិត្ត ដើម្បីរំដោះជីវិតឆ្ពោះទៅស្ថានបរមសុខពិតពោល គឺ **និព្វាន** ។

~ **ព្រះធម្មវិន័យ** គឺជាក្បួនច្បាប់វិន័យ ជាពាក្យប្រៀនប្រដៅដាស់តឿន ទូន្មាន របស់ព្រះពុទ្ធ អោយស្គាល់ផ្លូវដ៏ប្រសើរ ពោលគឺ អរិយមគ្គ ហៅថា **មជ្ឈិមប្បដិបទា** ឬ **អដ្ឋង្គិកមគ្គ** ដែលចែកជាសិក្ខាបទ ៣ យ៉ាង គឺ **សីល សមាធិ បញ្ញា** ដែលជាមធ្យោបាយជាមាគ៌ារំដោះទុក្ខ ។

~ អ្នកដែលប្រតិបត្តិត្រឹមត្រូវល្អតាមព្រះធម៌វិន័យ និង បួស រៀន សិក្សា ទ្រទ្រង់សិក្ខាបទតាមទស្សនវិជ្ជាព្រះពុទ្ធសាសនា ហៅថា **ព្រះសង្ឃ** ។ ព្រះសង្ឃ គឺជាសាវ័ករបស់ព្រះសម្មាសម្ពុទ្ធ, ជា **បុញ្ញក្ខេត្ត** ( ស្រែបុណ្យ ) របស់ពុទ្ធសាសនិកជន ។ ព្រះសង្ឃបុថុជ្ជន ហៅថា "សម្មតិសង្ឃ", ព្រះសង្ឃដែលប្រកបដោយគុណដ៏វិសេសវិសាលប្រសើរបំផុត ហៅថា "អរិយសង្ឃ" ។

## ៧ បញ្ញាគុណ វិសុទ្ធិគុណ ករុណាគុណ

~ **បញ្ញាគុណ** ជា **គុណធម៌** ដ៏កំពូលរបស់ព្រះសម្មាសម្ពុទ្ធ ជាអម្ចាស់ដែលបានត្រាស់ដឹងនូវមគ្គញ្ញាណ ដែលជាទីតាំងនៃសព្វញ្ញុតញ្ញាណ និង ញាណដ៏វិសេស មានចតុវេសារជ្ជញ្ញាណ ទសពលញ្ញាណ និង អនាវរណញ្ញាណជាដើម ( ស្រង់ចាកប្រស្នាត្រៃគុណ )។

~ **វិសុទ្ធិគុណ** ជា**គុណភាព**ដ៏បរិសុទ្ធរបស់ព្រះពុទ្ធអង្គ បានដល់ការលះបង់ដាច់ស្រឡះទាំងស្រុង នូវកិលេសតណ្ហា ឧបាទាន មិនប្រឡាក់ញាប់ញ័រនឹងលោកធម៌ទាំង ៨ ប្រការ ។

~ **ករុណាគុណ** ជា **គុណប្រយោជន៍** ដ៏វិសេសដែលព្រះសម្មាសម្ពុទ្ធជាព្រះបរមគ្រូ បានផ្តល់នូវសេចក្តីប្រោសប្រណីអាណិត

អាស្វរ ស្រោចស្រង់ដល់ពពួកសត្តនិករ អោយរួចចាកផុតពីទុក្ខវេទនាគ្រប់បែបយ៉ាងដែលផុតរោលរាល អោយក្រហល់ក្រហាយអន្ទះអន្ទែង ដោយភ្លើងទុក្ខ ភ្លើងកិលេស និង លង់ឈ្លក់នៅក្នុងវាលវដ្តសង្សារ រងទុក្ខវេទនាឥតត្រើយត្រាណ ក្នុងសមុទ្រភ្លើងតណ្ហា ។

## ៧ សីលគុណ សមាធិគុណ បញ្ញាគុណ

**១ ~ សីល** (ការអប់រំ រក្សាកាយ វាចាអោយមានរបៀបរៀបរយ) ≈ **វចីសុចរិត + កាយសុចរិត** ( <u>សម្មាវាចា</u> : និយាយពោលពាក្យត្រឹមត្រូវ ប្រកបដោយគុណធម៌ ដោយស្មោះសរ, <u>សម្មាកម្មន្តៈ</u> ការប្រព្រឹត្តនូវអំពើជាគុណធម៌ ជាកុសល ជាគុណប្រយោជន៍ដល់សង្គមជាតិ និង <u>សម្មាអាជីវៈ</u> ការចិញ្ចឹមជីវិតដោយសុចរិតត្រឹមត្រូវ មិនបំពុល មិនបំផ្លាញសង្គម) ។

**២ ~ សមាធិ ≈ មនោសុចិត ឬ ភាពសុចរិតនៃគំនិត** ( <u>សម្មាវាយាមៈ</u> សេចក្តីព្យាយាមក្នុងអំពើជាកុសល, <u>សម្មាសតិ</u> ការមានការប្រុងប្រយ័ត្នមិនធ្វេសប្រហែស មិនប្រមាទពេលវេលា មិនបណ្តោយអោយអវិជ្ជា តណ្ហា ឧបាទាន អូសទាញជីវិត និង <u>សម្មា</u>

## សច្ចធម៌ និង ពុទ្ធិគតិបណ្ឌិត

សមាធិ ៖ ការគ្រប់គ្រងប្រមូលផ្តុំអារម្មណ៍អោយនៅស្ងប់ជាឧបេក្ខា មិនភ្ញាក់ផ្អើលញាប់ញ័រ រំជើបរំជួលនឹងលោកធម៌ទាំង ៨ ប្រការ)។

៣ - **បញ្ញា (ភាពភ្លឺស្វាងបរិសុទ្ធ ឈ្លាសវៃ នៃសតិ-បញ្ញាស្មារតី)** ≈ សម្មាទិដ្ឋិ ៖ ការមានជំនឿដោយយល់ត្រឹមត្រូវ តាមផ្លូវហេតុ-ផល, សម្មាសង្កប្បៈ ការគិតត្រិះរិះពិចារណាប្រកបដោយវិចារណញ្ញាណ មានហេតុ-ផល និង មានសុភនិច្ច័យគ្រប់គ្រាន់ ។

## ❧ គុណធម៌ គុណភាព គុណប្រយោជន៍

- **គុណធម៌** នាំអោយមនុស្សមានសេចក្តីថ្លៃថ្នូរពិតប្រាកដ ។
- **គុណភាព** នាំអោយមានការជឿជាក់ និង គោរពគ្នា ។
- **គុណប្រយោជន៍** នាំអោយមានសាមគ្គីភាព ។

## ❧ គុណមាតា-បិតា គុណគ្រូបាធ្យាយ គុណអ្នកមានឧបការៈ

- **មាតា-បិតា** ជាអ្នកផ្តល់កំណើត និង អប់រំសព្វគ្រប់បែបយ៉ាង ដើម្បីអោយកូនទាំងឡាយក្លាយជាមនុស្សពេញលក្ខណៈ ដែលជា **គុណធម៌** សម្រាប់ជីវិត ។

# សច្ចធម៌ និង ពុទ្ធិគតិបណ្ឌិត

~ **គ្រូបាធ្យាយ** ជាអ្នកអប់រំ បង្ហាញផ្លូវ និង ផ្តល់នូវចំណេះវិជ្ជាសម្រាប់ជា **គុណភាព**នៃជីវិត ។

~ **លោកអ្នកមានឧបការៈ** (ជីដូន-ជីតា មាមីង ពូ អ៊ំ... ) ជាអ្នកជួយជ្រោមជ្រែង ឧបត្ថម្ភ ជួយរែកពុន ជួយចម្លងជីវិត ដើម្បីជា **គុណប្រយោជន៍** ដល់សង្គម ។

➤ **នីវរណៈ** ( សភាវៈដែលជាគ្រឿងរាំងរាហាមចិត្តមិនឱ្យបានលុះក្នុងសេចក្តីល្អ ហៅថានីវរណធម៌ មាន ៥ យ៉ាង ) :

- **កាមច្ឆន្ទៈ** : សេចក្តីស្រឡាញ់ចូលចិត្តក្នុងអារម្មណ៍ មានរូបជាដើម ដែលជាទីគាប់ចិត្ត ។
- **ព្យាបាទៈ** : ការចងចិត្តគុំគួន ចងអាឃាតនឹងអ្នកដទៃ ។
- **ថីនមិទ្ធៈ** : ដំណើរចិត្តដែលងោកងុយ រារែក រួញរា ។
- **ឧទ្ធច្ចកុក្កុច្ចៈ** : ដំណើរនៃចិត្តដែលរាយមាយ រសាប់រសល់ខ្វល់ខ្វាយ ។
- **វិចិកិច្ឆា** : ដំណើរចិត្តដែលមិនច្បាស់លាស់ ចេះតែសង្ស័យ។

## ➢ កាលាមសូត្រ :

ការមិនគួរជឿដោយអាការៈ ១០ យ៉ាង តាមទស្សនៈរបស់ព្រះពុទ្ធ :

- **មា អនុស្សវេន** កុំប្រកាន់ជឿអ្វីដែលស្ដាប់ឮ ត១ តាមគ្នា,
- **មា បរម្បរាយ** កុំប្រកាន់ជឿអ្វីតាមពាក្យបរម្បរា,
- **មា ឥតិកិរាយ** កុំប្រកាន់ជឿដោយការភ្ញាក់ផ្អើល,
- **មា បិដកសម្បទានេន** កុំប្រកាន់ជឿដោយអាងក្បួនតម្រា,
- **មា តក្កហេតុ** កុំប្រកាន់ជឿតាមការត្រិះរិះ អត្តនោម័តិ
- **មា នយហេតុ** កុំប្រកាន់ជឿដោយការកាត់ផ្សំន័យ,
- **មា អាការបរិវិតក្កេន** កុំប្រកាន់ជឿអ្វីតាមការមើលឃើញនូវពហិលក្ខណៈ ជាអាការៈខាងក្រៅ,
- **មា ទិដ្ឋិនិជ្ឈានក្ខន្តិយា** កុំប្រកាន់ជឿដោយការពេញចិត្តស្របតាមទិដ្ឋិមានះរបស់ខ្លួន,
- **មា ភព្វរូបតាយ** កុំប្រកាន់ជឿដោយយល់ថាត្រូវតែជឿ,
- **មា សមណោ នោ គរុ** កុំប្រកាន់ជឿដោយគ្រាន់តែឃើញថាជាសមណៈអ្នកបួស ក៏យល់ថាជាគ្រូនោះ ។

## ➢ គុណធម៌ ៤ ជាព្រហ្មវិហារធម៌ :

- **មេត្តា** : សេចក្ដីស្រឡាញ់ដោយស្មោះត្រង់ ស្មើភាពជាទូទៅដោយឥតរើសមុខ ឥតប្រកាន់បក្ខពួក (*Benevolence*) ។
- **ករុណា** : សេចក្ដីអាណិតអាសូរ និង ជួយយកអាសាដល់អ្នកទុគ៌ត មានទុក្ខវេទនាទាំងឡាយ (*Compassion*) ។
- **មុទិតា** : សេចក្ដីត្រេកអរតាមអ្នកដែលមានសេចក្ដីសុខប្រកបដោយបីតិស្មោះសរ (*Sympathy*) ។
- **ឧបេក្ខា** : ការតាំងចិត្តជាកណ្ដាល ស្មើ មិនញាប់ញ័រនឹងលោកធម៌ ទាំង៨ ប្រការ, មិនលំអៀងដោយអគតិ ៤ ( ឆន្ទាគតិ ភយាគតិ ទោសាគតិ មោហាគតិ ) (*Equanimity*) ។

## ➢ អរិយទ្រព្យ ៧ យ៉ាង :

គឺជាទ្រព្យ (អរូប)ដ៏ប្រសើរ តាមផ្លូវព្រះធម៌ ដែលមានតម្លៃថ្លៃលើសលប់ លើសទ្រព្យសម្ភារៈដែលមើលឃើញ ។

- **សទ្ធាធនំ** : មានសទ្ធាជ្រះថ្លា ជាជំនឿប្រកបដោយហេតុ-ផល ជាទ្រព្យ ,
- **សីលធនំ** : មាន **សីលធម៌ គុណធម៌** ជាទ្រព្យ
- **ហិរិធនំ** : មាន "**ហិរិ**" ខ្មាសបាប ជាទ្រព្យ
- **ឱត្តប្បធនំ** : មាន "**ឱត្តប្បៈ**" ខ្លាចបាប ជាទ្រព្យ
- **សុតធនំ** : មានការចេះស្ដាប់ រៀនសូត្រចេះចាំនូវសីលវិជ្ជាផ្សេងៗ ប្រកបដោយគតិបណ្ឌិត
- **ចាគធនំ** : មានការលះបង់ ដោយសេចក្ដីសន្ដោសគ្នា
- **បញ្ញាធនំ** : មានបញ្ញាសុភនិច្ឆ័យ វិភាគ យល់ដឹងស្គាល់ នូវរាល់បញ្ហាទាំងឡាយ ។

## ➢ សប្បុរិសធម៌ ៧ យ៉ាង របស់បណ្ឌិត

### ឬ ធម៌ ៧ យ៉ាង របស់សប្បុរសជន ៖

- **ធម្មញ្ញុតា** : ភាពជាអ្នកស្គាល់នូវ "ហេតុ" នៃបញ្ហា
- **អត្ថញ្ញុតា** : ភាពជាអ្នកស្គាល់នូវ "ផល" នៃបញ្ហា
- **អត្តញ្ញុតា** : ភាពជាអ្នកស្គាល់នូវ "ខ្លួនឯង" ច្បាស់លាស់
- **មត្តញ្ញុតា** : ភាពជាអ្នកចេះប្រមាណ ( Sobre )
- **កាលញ្ញុតា** : ភាពជាអ្នកស្គាល់នូវពេលវេលា
- **បរិសញ្ញុតា** : ភាពជាអ្នកស្គាល់នូវទីប្រជុំនៃមជ្ឈដ្ឋាន
- **បុគ្គលបរោបរញ្ញុតា** : ភាពជាអ្នកស្គាល់បុគ្គល ស្គាល់មនុស្ស ស្គាល់អ្នកដទៃ ។

## ➤ វិជ្ជា ៨ ប្រការ :

- **វិបស្សនាញ្ញាណ**: ពិចារណាឃើញនូវ "**នាមរូប**" ,
- **មនោមយិទ្ធិ** : ឫទ្ធិ៍សម្រេចដោយកម្លាំងចិត្ត,
- **ឥទ្ធិវិធី** : ឫទ្ធិសម្រេចដោយការឧទ្ទិសអធិដ្ឋាន,
- **ទិព្វសោត** : ត្រចៀកទិព្វ ត្រចៀកវៃ,
- **ចេតោបរិញ្ញាណ** : ប្រមាណយល់ដឹងបាននូវចិត្តអ្នកដទៃ,
- **បុព្វេនិវាសានុស្សតិញ្ញាណ** ប្រាជ្ញារលឹកឃើញនូវអតីតជាតិ,
- **ទិព្វចក្ខុ** : ភ្នែកទិព្វ ភ្នែកវៃរហ័ស,
- **អាសវក្ខញ្ញាណ** : ដឹងនូវការអស់ទៅនៃអាសវៈ ។

## ➢ សង្ខេបព្រះពុទ្ធឱវាទ ៣ យ៉ាង ៖

- **សព្វបាបស្ស អករណំ** ៖ មិនត្រូវប្រព្រឹត្តអំពើអាក្រក់ជាអំពើទុច្ចរិតដោយកាយ វាចា ចិត្ត,
- **កុសលស្សូបសម្បទា** ៖ ញុំាងកុសលឱ្យកើតព្រម គឺប្រកបដោយភាពសុចរិត នៃ កាយ វាចា ចិត្ត,
- **សចិត្តបរិយោទបនំ** ៖ ជម្រះចិត្តរបស់ខ្លួនអោយល្អ ផូរផង់បរិសុទ្ធ ចាកគ្រឿងសៅហ្មង មាន លោភៈ ទោសៈ មោហៈ ជាដើម ។

## ➢ សុចរិត ៣ យ៉ាង :

១~ **<u>កាយសុចរិត</u>** : ការប្រព្រឹត្តល្អដោយផ្លូវ កាយ ៣យ៉ាង:

១. វៀរចាកការបៀតបៀនជីវិតមនុស្ស-សត្វ ។

២. វៀរចាកការលួចបន្លំកេងប្រវ័ញ្ចទ្រព្យគេ ។

៣. វៀរចាកការប្រព្រឹត្តខុសសីលធម៌ក្នុងកាម ។

២~ **<u>វចីសុចរិត</u>** : ការប្រព្រឹត្តល្អដោយផ្លូវ វាចា ៤យ៉ាង :

១. វៀរចាកការនិយាយភូតភរ បំផ្លើស បោកប្រាស់គេ។

២. វៀរចាកការនិយាយញុះញង់គេឱ្យមានទំនាស់ ។

៣. វៀរចាកការនិយាយស៊កសៀតចាក់ដោតគេ ។

៤. វៀរចាកការនិយាយពោលពាក្យឥតប្រយោជន៍ ។

៣~ **<u>មនោសុចរិត</u>** : ការប្រព្រឹត្តល្អដោយផ្លូវ ចិត្ត ៣យ៉ាង :

១. មិនសម្លឹងរំពៃចង់បានរបស់គេ មិនពុករលួយ ...

២. មានចិត្តសន្តោស មិនចងចិត្តប្រទូស្តនឹងអ្នកដទៃ ។

៣. មានភាពសុចរិតនៃគំនិត មានសុភនិច្ឆ័យ ។

## ➢ ទុច្ចរិត ៣ យ៉ាង :

១. **កាយទុច្ចរិត** : ការប្រព្រឹត្តអាក្រក់ ៣ យ៉ាងដោយផ្លូវ កាយ

- **បាណាតិបាត** : សម្លាប់សត្វមានជីវិត ។
- **អទិន្នាទាន** : លួចទ្រព្យគេ ។
- **កាមេសុ មិច្ឆាចារ** : ប្រព្រឹត្តខុសច្បាប់ ខុសសីលធម៌ ក្នុងកាម ។

២. **វចីទុច្ចរិត** : ការប្រព្រឹត្តអាក្រក់ ៤ យ៉ាង ដោយផ្លូវ វាចា

- **មុសាវាទ** : និយាយកុហកគេ ។
- **បិសុណវាចា** : និយាយញុះញង់គេ ។
- **ផរុសវាចា** : និយាយចាក់ដោតគេ ។
- **សម្ផប្បលាប** : និយាយពាក្យឥតប្រយោជន៍ ។

៣. **មនោទុច្ចរិត** : ការប្រព្រឹត្តអាក្រក់ ៣ យ៉ាង ដោយផ្លូវ ចិត្ត

- **អភិជ្ឈា** : សម្លឹងរំពៃចង់បានរបស់គេ ។
- **ព្យាបាទ** : ចងចិត្តប្រទូស្តគេ ។
- **មិច្ឆាទិដ្ឋិ** : អស្មិមានះយល់ឃើញខុសប្រាសចាកគន្លងធម៌ ។

## ➢ កុសលមូល ៣ យ៉ាង ៖

( ប្រភពចិត្តបុណ្យ ចិត្តជាកុសល )

- **អលោភៈ** ៖ ចេះគ្រប់គ្រាន់ ចេះទប់ចំណង់ មិនលោភលន់។
- **អទោសៈ** ៖ មិនឆេវឆាវ ចេះបន្ទាប បង្ក្រាបភ្លើងកំហឹង ។
- **អមោហៈ** ៖ មានបញ្ញា-វិចារណញ្ញាណភ្លឺស្វាង ។

## ➢ អកុសលមូល ៣ យ៉ាង ៖

( **ប្រភពនៃចិត្តបាប សាបព្រោះអកុសល** )

- **លោភៈ** ៖ ចង់បានមិនចេះស្កប់ស្កល់ មិនចេះគ្រប់គ្រាន់។
- **ទោសៈ** ៖ ខឹងក្រេវក្រោធ គិតប្រទូស្តនឹងអ្នកដទៃ។
- **មោហៈ** ៖ ឆេវឆោតល្ងង់ខ្លៅស្រវឹងវង្វេងមិនដឹងសេចក្ដីពិត ។

## ➢ លក្ខណៈវិនិច្ឆ័យ ៣ ដំណាក់កាល សម្រាប់សិក្សា និង វាយតម្លៃមនុស្ស :

- **អាកប្បកិរិយា** : ការសំគាល់លក្ខណៈតាម អាការៈខាងក្រៅ ។
- **វាចា ភាសាគំនិត** : តាមការពោលពាក្យនិយាយស្តី ។
- **ការប្រព្រឹត្តជាក់ស្តែង** : ជាការឆ្លុះបញ្ចាំងនូវចរិតខាងក្នុង។

## ➢ មេរៀនអំពីកំហុស

ក្នុងរាល់ការប្រព្រឹត្ត មនុស្សគ្រប់រូបសុទ្ធតែមានកំហុស គ្រាន់តែតិច ឬច្រើន ដោយចេតនា ឬដោយអចេតនា តែប៉ុណ្ណោះ, តែប្រការសំខាន់នោះ គឺត្រូវ :

១- ចេះទទួលស្គាល់នូវកំហុសរបស់ខ្លួនដែលកើតមានឡើង,
២- សិក្សាពីកំហុសនោះ ដើម្បីដកស្រង់យកនូវមេរៀន,
៣- កុំអោយកំហុសដដែលនោះកើតឡើងសាជាថ្មីទៀត ។

## ➢ លក្ខណៈមនុស្ស ៤ ប្រភេទ :

- **<u>មនុស្សទេវោ</u>** : មនុស្សដែលមានលក្ខណៈទាំងរាងកាយ ទាំងដួងចិត្ត-ព្រលឹង ប្រកបដោយគុណធម៌ ខ្ពង់ខ្ពស់ ថ្លៃថ្នូរ ដូចជាទេវៈ,

- **<u>មនុស្សមនុស្សោ</u>** : មនុស្សដែលមានកាយ-ចិត្ត ប្រកបដោយលក្ខណៈជាមនុស្សពេញលេញ និង មានគំនិតមនុស្សធម៌ ,

- **<u>មនុស្សតិរច្ឆានោ</u>** : មនុស្សដែលមានតែរាងកាយជាមនុស្ស តែដួងចិត្ត-ព្រលឹងប្រកបដោយសភាវគតិ រស់នៅថោកទាប ដូចជាសត្វតិរច្ឆាន ដែលពុំស្គាល់គុណ-ទោស ខុស-ត្រូវ ល្អ-អាក្រក់អ្វីទាំងអស់ ។

- **<u>មនុស្សបេតោ</u>** : មនុស្សដែលមានតែរាងកាយជាមនុស្ស តែចិត្ត-ព្រលឹងប្រកបដោយអកុសល បាបកម្មក្រាស់ រស់នៅស្រេកឃ្លានបរិភោគតែគ្រឿងស្មោកគ្រោក លាមក ភក់ជ្រាំ ខ្ទុះឈាម... ដូចជាប្រេតក្នុងស្ថាននរក ។

## ➤ ចរិតលក្ខណៈបុគ្គល ៦ យ៉ាង ៖

១. **រាគចរិត** ៖ ចរិតដែលប្រព្រឹត្តដោយរាគៈ លោភលន់។

២. **ទោសចរិត** ៖ ចរិតដែលប្រកបដោយទោសៈ (ភ្លើងកំហឹង)។

៣. **មោហចរិត** ៖ ចរិតដែលប្រព្រឹត្តដោយមោហៈ (វង្វេង)។

៤. **វិតក្កចរិត** ៖ ចរិតដែលប្រព្រឹត្តដោយការត្រិះរិះ ។

៥. **សទ្ធាចរិត** ៖ ចរិតដែលប្រកបដោយសទ្ធា ។

៦. **ពុទ្ធិចរិត** ៖ ចរិតដែលប្រកបដោយពុទ្ធិបញ្ញា។

## ➤ អគតិ ៤ យ៉ាង ៖

**អគតិ** គឺការលំអៀង ការប្រកាន់ ក្នុងផ្លូវខុស

- **ឆន្ទាគតិ** ៖ លំអៀង ព្រោះស្រឡាញ់ ។
- **ទោសាគតិ** ៖ លំអៀង ព្រោះស្អប់ ។
- **មោហាគតិ** ៖ លំអៀង ព្រោះល្ងង់ ។
- **ភយាគតិ** ៖ លំអៀង ព្រោះខ្លាច ។

## ➢ ពាក្យដែលគួរពោល ១០ យ៉ាង :

- **អប្បិច្ឆកថា** : ពាក្យដែលនាំឱ្យមានប្រាថ្នាតិច,
- **សន្តុដ្ឋិកថា** : ពាក្យដែលនាំឱ្យមានសេចក្ដីសន្ដោស,
- **បវិវេកកថា** : ពាក្យដែលនាំឱ្យមានការគិត ពិចារណា សង្វេគពីកាយ-ចិត្ត,
- **អសំសគ្គកថា** : ពាក្យដែលនាំមិនឱ្យប្រកាន់បក្សពួក,
- **វីរិយារម្ភកថា** : ពាក្យដែលនាំឱ្យប្រារព្ធនូវការព្យាយាម
- **សីលកថា** : ពាក្យដែលនាំឱ្យស្វែងរកសីល,
- **សមាធិកថា** : ពាក្យដែលនាំឱ្យធ្វើចិត្តស្ងប់,
- **បញ្ញាកថា** : ពាក្យដែលនាំឱ្យកើតបញ្ញាភ្លឺស្វាង,
- **វិមុត្តិកថា** : ពាក្យដែលនាំឱ្យចិត្តចេញផុតចាក កិលេស,
- **វិមុត្តិញ្ញាណទស្សនកថា** : ពាក្យដែលនាំឱ្យកើត សេចក្ដីដឹង ឃើញ ក្នុងការដែលចិត្ត ចេញចាកផុតកិលេសតណ្ហា,

➢ "អនុស្សតិ" អារម្មណ៍ដែលគួររលឹក ១០ យ៉ាង :

- **ពុទ្ធានុស្សតិ** : រលឹកដល់គុណព្រះពុទ្ធ ។
- **ធម្មានុស្សតិ** : រលឹកដល់គុណព្រះធម៌ ។
- **សង្ឃានុស្សតិ**: រលឹកដល់គុណព្រះសង្ឃ ។
- **សីលានុស្សតិ**: រលឹកដល់គុណនៃសីល ។
- **ចាគានុស្សតិ** : រលឹកដល់គុណនៃការបរិច្ចាគលះបង់
- **ទេវានុស្សតិ** : រលឹកដល់គុណធម៌
  ដែលញ៉ាំងអោយបុគ្គលខ្ពង់ខ្ពស់ ថ្លៃថ្នូរ ។
- **មរណានុស្សតិ** : រលឹកដល់សេចក្ដីស្លាប់
  ដើម្បីរស់អោយបានត្រឹមត្រូវ ។
- **កាយគតាសតិ** : រលឹកចំពោះកាយឱ្យឃើញថា
  ជារបស់មិនស្អាត គួរខ្ពើមរអើម ។
- **អានាបានុស្សតិ** : តម្កល់សតិ កំណត់ការដក
  ដង្ហើមចេញ-ចូល ។
- **ឧបសមានុស្សតិ** : រលឹកដល់ព្រះនិព្វាន
  ជាស្ថានរំលត់ទុក្ខ ។

## ➢ "កម្មដ្ឋាន" ដែលត្រូវរក្សាទុកក្នុងខ្លួនជានិច្ច :

- **ពុទ្ធានុស្សតិ** : ការរលឹកដល់គុណរបស់ព្រះសម្មាសម្ពុទ្ធជាព្រះបរមគ្រូជានិច្ច ។
- **មេត្តា** : ផ្សាយមេត្តាចិត្តដល់សព្វសត្វ ។
- **អសុភៈ** : ពិចារណាឱ្យឃើញថារាងកាយជាវត្ថុមិនល្អ ។
- **មរណស្សតិ** : រំឭកពិចារណាអំពីសេចក្ដីស្លាប់ ។

## ➤ "ឧបក្កិលេស" គ្រឿងសៅហ្មងនៃចិត្តជាទោស ១៦ :

១. លោភះ : ការលោភលន់ ចង់បាន មិនចេះស្កប់ស្កល់ ។
២. ទោសះ : ខឹងក្រេវក្រោធ គិតប្រទូស្ត ។
៣. មោហះ : វង្វេង ងងឹត ភ័ន្តភាំងស្មារតី ។
៤. ឧបនាហះ : ចិញ្ចឹមសេចក្តីក្រោធទុក ។
៥. មក្ខះ : រមិលគុណគេ ។
៦. បលាសះ : លើកកំពស់ខ្លួនហួសគុណសម្បត្តិដែលខ្លួនមាន
៧. ឥស្សា : ប្ញស្សា ច្រណែនឈ្នានីស ។
៨. មច្ឆរិយះ : ស្វិត កំណាញ់ ។
៩. មាយា : លាក់ពុត បិទបាំងទោសកំហុសខ្លួន ។
១០. សាថេយ្យ : អំនួតអួតអាង ។
១១. ថម្ភះ : រឹងរូស ។
១២. សារម្ភះ : ចចេស ។
១៣. មានះ : ការប្រកាន់ខ្លួន ។
១៤. អតិមានះ : ប្រមាថមើលងាយអ្នកដទៃ ។
១៥. មទះ : ស្រវឹងនឹងតណ្ហា ។
១៦. បមាទះ : ប្រមាទ ធ្វេសប្រហែស មើលងាយខ្លួនឯង។

## ☸ បញ្ហា ធម្មា ភាវេតព្វា : ធម៌ ៥ យ៉ាង គួរចំរើន...

ដើម្បីដឹងច្បាស់នូវ **ឧបក្កិលេស** ១៧ យ៉ាង : **រាគៈ** (តម្រេក), **ទោសៈ** (សេចក្តីប្រទូស្តក្នុងអារម្មណ៍), **មោហៈ** (វង្វេងក្នុងអារម្មណ៍) **កោធៈ** (ខឹងក្រេវក្រោធ), **ឧបនាហៈ** (ចងសេចក្តីក្រោធទុក), **មក្ខៈ** (រមិលគុណ), **បលាសៈ** (លើកខ្លួន), **ឥស្សា** (ប្ញស្សា), **មច្ឆរិយៈ** (កំណាញ់), **មាយា** (លាក់ពុតល្បិចកល), **សាថេយ្យៈ** (អំនួតអួតអាង), **ថម្ភៈ** (រឹងត្អឹង), **សារម្ភៈ** (ប្រកួតប្រជែង), **មានៈ** (ប្រកាន់ខ្លួន), **អតិមានៈ** (មើលងាយអ្នកដទៃ), **មទៈ** (ស្រវឹង), **បមាទៈ** (ប្រាសចាកសតិ) ។

ម្នាលភិក្ខុទាំងឡាយ **ធម៌ ៥** យ៉ាង គួរចំរើន ដើម្បីដឹងច្បាស់ នូវ **ឧបក្កិលេស** ១៧ ពួក ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ? គឺ :

១.. **អសុភសញ្ញា សំគាល់ឃើញថាមិនស្អាត** ១,
២.. **មរណសញ្ញា សំគាល់ឃើញក្នុងសេចក្តីស្លាប់** ១,
៣.. **អាទីនវសញ្ញា សំគាល់ឃើញថាមានទោស** ១,
៤.. **អាហារេ បដិក្កូលសញ្ញា** សំគាល់ឃើញថាគួរខ្ពើម ក្នុងអាហារ
៥.. **សព្វលោកេ អនភិរតសញ្ញា** សំគាល់ឃើញថាមិនគួរត្រេកអរ**ក្នុងលោកទាំងពួង** ១ ។

## ➢ "និព្វាន" ជាអ្វី ?

សព្ទថាព្រះនិព្វានជាបរមសុខនោះ គឺសំដៅយកនូវសារជាតិជាឧត្តមគតិនៃគុណធម៌ ដ៏ប្រសើរខ្ពង់ខ្ពស់បំផុត ដែលកំចាត់បង់ដាច់ស្រឡះនូវភាព **អវិជ្ជា តណ្ហា ឧបាទាន** ដែលចងក្រៀកសត្វលោកអោយជាប់ចំណងរឹងក្រញង់ ស្រវឹង វង្វេង ។

ព្រះនិព្វានបញ្ឈប់នូវវដ្តមាននៃទុក្ខទាំងអស់ ដោយបំបាត់នូវតណ្ហា (**លោភៈ ទោសៈ មោហៈ**) ដែលជាមូលហេតុជាឫសកែវនៃសេចក្តីទុក្ខនេះឯង ។

តាមន័យសព្ទ **និព្វាន** ជាពាក្យបាលី ដែលបែកចេញមកពីពាក្យសំស្ក្រឹតថា "និវ៌ាណ" ដែលមានន័យមកពីធាតុ ២ ថា = < និ : *ចាកផុត ចេញផុត កាត់ផ្តាច់* + វាណ : *ត្បាញចងភ្ជាក់ស្រេះ ជំពាក់ដោយសេចក្តីប្រាថ្នា, ជាចំណងដែលចងជីវិតរបស់យើងភ្ជាប់ពីវដ្តមួយទៅមួយទៀត* ។

**និព្វាន** គឺជាធម៌ដែលជួយយើង អោយរបូតរួចផុតពី សេចក្តីប្រាថ្នាមិនចេះឈប់ឈរ ឬដែលជួយដោះយើងអោយ របូតរួចពីចំណងនៃសេចក្តីប្រាថ្នាគ្មានព្រំដែន (**តណ្ហា** )។

ព្រះនិព្វាន អាចពន្យល់បានថាជាទឹកអម្រឹតដ៏ថ្លាឆ្វង់ ត្រជាក់បរិសុទ្ធ ដែលសម្រាប់**បន្សុទ្ធ**បញ្ញា **បន្សាប**ពិសពុល តណ្ហា **បន្សល់**នូវភាពបរិសុទ្ធនៃគតិបណ្ឌិត **រំលត់**ភ្លើងកិលេស តណ្ហា មានការលោភលន់ចង់បានមិនចេះស្កប់ស្កល់ (លោភៈ) រំលត់ភ្លើងកំហឹង ដែលដុតរោលរាលសន្តានចិត្ត អោយឆេះក្តៅ ក្រហល់ក្រហាយ អន្ទះអន្ទែង (ទោសៈ) **រំលាយ**ផ្សែងខ្មៅ ( មោហៈ) ដែលបិទបាំងរាំងស្ទះ ធ្វើមិនអោយមើលឃើញផ្លូវ សច្ចធម៌ ។

**និព្វាន** គឺជាការកាប់ផ្តួលរម្លំ ផ្តុំរំលើងនូវឫសកែវ អកុសលធម៌ បាបធម៌ទាំងពួង រំលត់រំលាយភ្លើង**តណ្ហា**អោយ រលត់ ហើយកាត់ផ្តាច់បំបាក់ បំបាត់ ទាំងស្រុងនូវច្រវាក់ **អវិជ្ជា ឧបាទាន** ។

**មនុស្សអវិជ្ជា មិនជឿថាមានព្រះនិព្វានឡើយ ប្រៀប ដូចជាមនុស្សខ្វាក់ដែលគិតថាមិនមានពន្លឺ ព្រោះមនុស្សខ្វាក់ មិនដែលមានឱកាសបានឃើញនូវពន្លឺពិតប្រាកដឡើយ ។**

ដូចនេះនិព្វានពុំមែនជាទីស្ថាន មានអាសយដ្ឋានដូច ជា ស្រុក ភូមិ ឃុំ ខណ្ឌ ខេត្ត ឬប្រទេសណាមួយនោះទេ ... **ថានៅជិត ឬថានៅឆ្ងាយក៏ពុំបាន** អាស្រ័យដោយកម្រិតនៃ គុណធម៌ដ៏ភ្លឺស្វាង នៃការយល់ដឹង ភ្ញាក់រឭក ប្រកបដោយពុទ្ធិ និង គតិបណ្ឌិត របស់បុគ្គលម្នាក់ៗ ។

និព្វាន គឺជា លោកុត្តរធម៌ ដែលជាធម៌សម្រាប់ ចម្លងគំនិត ជីវិតបុគ្គលសត្តនិករទាំងឡាយណា ដែលមើល ឃើញសច្ចធម៌ មើលឃើញទោសនៃតណ្ហា ហើយស្វែងរកភាព ភ្លឺស្វាងនៃគំនិតសតិ-បញ្ញា ដោយប្រឹងកាប់ឆ្ការបន្ទាអវិជ្ជា និង ឧបាទាន ចោលចេញ អោយស្រឡះពីមាគ៌ានៃជីវិតនេះ ។

**និព្វាន** គឺជាសភាវៈនៃចិត្ត របស់បុគ្គលអ្នកជាដែល មានចិត្តជា មានបញ្ញាភ្លឺថ្លា មានមេត្តា ករុណា មុទិតា ឧបេក្ខា ធម៌ មានសេរីភាព មានឥស្សរភាពបរិបូណ៌ដែលពុំរស់ស្ថិតនៅ ក្រោមឥទ្ធិពលនៃតណ្ហា(លោភៈ ទោសៈ មោហៈ) ដែលរលាស់ ខ្លួនចេញផុតពីអន្ទាក់ នៃភាពអវិជ្ជា ឧបាទាន ។

មធ្យោបាយទៅកាន់ព្រះនិព្វាន ពុំអាចទៅបានដោយសារមាសប្រាក់ ធ្វើលិខិតឆ្លងដែន ជិះយន្តហោះ ជិះរថយន្ត កប៉ាល់ សំពៅ ទូកសំប៉ានបានឡើយ... ហើយក៏មិនអាចយកលុយកាក់ មាសពេជ្រ ទ្រព្យធន ទៅទិញ ទៅដូរយកនិព្វាន ក៏មិនបាន ឬក៏យកអំណាចយសស័ក្តិទៅបង្ក្រាប រឹបអូស រំលោភយកក៏មិនបាន... ។

បុគ្គលណាដែលមានមិច្ឆាទិដ្ឋិ អស្មិមានះ គិតឃើញថា គំនរមាសប្រាក់ យសស័ក្តិ ទ្រព្យធនរបស់ខ្លួនដែលបានមកពីមិច្ឆាកម្មន្តៈ មិច្ឆាអាជីវៈ ថាជាការអាចធ្វើអ្វីបានតាមចិត្តចង់ រួមទាំងនិព្វានផងនោះ នោះគឺជាការ **ប្រមាទ** លើ **ប្រមាថ** យ៉ាងធ្ងន់ បំពានលើសច្ចធម៌ និង គុណធម៌នៃនិព្វាន ហើយក៏មិនអាចជួបនឹងព្រះបរមនិព្វានបានឡើយ ។

**និព្វាន** គឺសម្រេចបានដោយកម្លាំងចិត្តប្រកបដោយការបំពេញបារមី ដែលជាគុណជាតិដ៏ល្អប្រសើរ ដែលបុគ្គលគួរបំពេញដោយការសំអិតសំអាត កិរិយា ចរិយា មារយាទ ដោយពេញលេញ សុក្រឹត គ្មានខ្វះចន្លោះ គ្មានល្អក់កករ ពោលគឺ : **ទាន សីល នេក្ខម្ម បញ្ញា វិរិយៈ ខន្តី សច្ចៈ អធិដ្ឋាន មេត្តា និង ឧបេក្ខាបារមី** ... ដោយឈានទៅតាមផ្លូវ មជ្ឈិម-ប្បដិបទា ឬ អដ្ឋង្គិកមគ្គ ដោយមាន "**សម្មាទិដ្ឋិ**" ជាតួ **បញ្ញា**

ជាអ្នកនាំមុខ ។ និយាយរួម **និព្វាន** គឺជាការប្រយុទ្ធជាអចិន្ត្រៃយ៍ យ៉ាងប្តូរផ្តាច់មុតមាំ ច្បាំងនឹងអាត្មាខ្លួនឯង ដើម្បីបន្សាបកាត់ផ្តាច់នូវ "ភាពអវិជ្ជា : *អត្តទត្តបុគ្គលនិយម អញនិយម អាត្មានិយម តណ្ហានិយម ជោរអួតអាងនិយម...* " កាត់ផ្តាច់នូវចំណងច្រវាក់នៃតណ្ហា អំនួត ជំនោរ មោទនភាពនឹង "**អញ**" ការស្រើបស្រាល ការភ្ញាក់ផ្អើលរន្ធត់ញាប់ញ័រនឹងលោកធម៌ ដែលចងចាក់ស្រេះរុំព័ទ្ធយ៉ាងជ្រៅនៅក្នុងសន្តាន។

សរុបមកវិញ **និព្វាន** គឺជាលទ្ធផលសំយោគ នៃការសន្សំព្យាយាមអំណត់ខន្តី ដើម្បីអប់រំជីវិតអោយសម្រេចបានដោយជោគជ័យ នូវ "***សីល សមាធិ*** និង ***បញ្ញា*** " ដែលជាអង្គធាតុសំខាន់នៃអដ្ឋង្គិកមគ្គ ឬមជ្ឈិមបដិបទានេះឯង ។

**និព្វាន** គឺជាចម្លើយតែមួយគត់ សម្រាប់អ្នកដែលច្បាំងឈ្នះខ្លួនឯង ឈ្នះតណ្ហាស្នោកគ្រោក ថោកទាប លាមកអវិជ្ជា ពាលា ភាពទ្រុស្តសីលទាំងឡាយ...

តាមទស្សនៈព្រះភិក្ខុធម្មបាល **ខៀវ-ជុំ** ក្នុងសៀវភៅ "និព្វាននៅឯណា?" បោះពុម្ពផ្សាយក្នុង ព.ស. ២៥១៧ / គ.ស. ១៩៧៣ លោកបានពន្យល់ថា **និព្វាន** ជាការរំលត់រំលាយយ៉ាងកំពូលនូវភាពក្តៅក្រហាយ ស្ពាបនាឱ្យសត្តានូវភាពត្រជាក់ត្រជំ

ក្រេមក្សាន្តយ៉ាងកំពូលរបស់ជីវិត ។ ភាពត្រជាក់ជាកំពូល នៃរបស់ទាំងឡាយនេះ កើតមានឡើងព្រោះមិនបានត្រូវភ្លើង គឺ : **លោភៈ ទោសៈ មោហៈ** ដុតបង្កាត់ឱ្យក្តៅ ។ គឺភ្លើងទាំងបីនេះហើយ ដែលដុតបំពក់កំទេចវិញ្ញាណមនុស្ស ឱ្យក្លាយទៅជាវិញ្ញាណសត្វនរក ។

*- និព្វានជាដែនស្ងប់ ជាទីគ្មានទុក្ខ ជាទីរំលត់សង្ខារ ជាទីរំលាយអវិជ្ជា ឬវាលវដ្តសង្សារ ។*

*- **និព្វាន**ជាគ្រឿងឧបករណ៍ ជាធម្មជាតិធ្វើឱ្យអស់នូវសកលកិលេស អស់គ្រឿងអាសវៈបាន ។*

*- **និព្វាន** ជាកិរិយាអាការៈ គឺជាចំណុចអស់កិលេស រលត់សង្ខារ សូន្យឧបាទាន រលាយនូវកិលេសកំពូល គឺ លោភៈ ទោសៈ មោហៈ ។*

*- **និព្វាន** ជាផលនៃការអស់កិលេស ជាបរមសុខ ជាភាពត្រជាក់ត្រជុំ គ្មានគ្រឿងចាក់ដោត គ្មានគ្រឿងដុតបំពក់ ជាធាតុមានឥស្សរភាព មានសេរីភាពយ៉ាងកំពូល ។*

**និព្វាន ជារឿងរបស់មនុស្សរស់ មិនមែនជារឿងរបស់មនុស្សស្លាប់ទេ** ។ និព្វានជារឿងដែលត្រូវដឹងចំពោះខ្លួន អ្នកដទៃពុំអាចដឹងជំនួសខ្លួនបានឡើយ ។ **និព្វាន** គឺជាភាព

ត្រជាក់ដែលកើតមានភ្លាម ១ ជាមួយនឹងភាពរលត់នូវភ្លើងកិលេស ។ ភាពត្រជាក់នៃនិព្វាន គេត្រូវស្វែងរកក្នុងភាពក្តៅ។ កំដៅមាន នៅក្នុងទីនេះ ក្នុងជីវិតនេះ ។

សកលសត្វនៅជិតឬនៅឆ្ងាយ អំពីនិព្វានប៉ុនណា គ្មានអ្នកណាដឹងជំនួសនរណាឡើយ ។ ដំណឹងអំពីនិព្វាន គឺត្រូវដឹងដោយខ្លួនឯង ។

ចំណែកឯ **ព្រះមហាឃោសានន្ទមហាយ៉ាន** លោកបានមានព្រះសង្ឃដីកាថា និព្វានគឺ **<u>នៅទីហ្នឹង</u>** **<u>នៅវេលាហ្នឹង</u>** (Nibban is **<u>NOW</u>** and **<u>HERE</u>** ) ព្រោះថា និព្វានគឺជាសភាពនៃចិត្តដែលគ្រប់គ្រង ទូន្មានបានអប់រំបានដោយល្អប្រពៃហើយ គឺជាការធ្វើជាម្ចាស់លើខ្លួនឯង បើកបរកាច់ចង្កូតជីវិតដោយខ្លួនឯង មិនធ្វើជាទាសករនៃតណ្ហា ។

និព្វានមានពីរប្រការ គឺ :~ <u>សឧបាទិសេសនិព្វាន</u>[១] ( < **ស** + **ឧបាទិសេស** + **និព្វាន** = សោបាទិសេសនិព្វាន ), និង <u>អនុបាទិសេសនិព្វាន</u> ។

➪ <u>**សឧបាទិសេសនិព្វាន**</u> ជាលោកិយនិព្វានដែលរលត់វីងស្ងួតនូវកិលេសតណ្ហា តែនៅសេសសល់ខន្ធ ៥ និង កងទុក្ខ សម្រេចដោយការត្រាស់ដឹង មគ្គ ៤, ផល ៤ ជាមូលហេតុ។

( **ស** ) <u>**ឧបាទិសេសនិព្វាន**</u> បានដល់កិរិយាដែលរីងស្ងួតនូវកិលេសតណ្ហា តួយ៉ាងដូចព្រះភគវន្តមុនី ព្រះអង្គទ្រង់គង់លើរតនបល្ល័ង្ក ក្រោមពោធិព្រឹក្សដ៏ប្រសើរ ទ្រង់ផ្ចាញ់មារាធិរាជ ព្រមទាំងវរហ៍ពល ( គឺកិលេសតណ្ហាទាំងឡាយនេះឯង ) ឱ្យបរាជ័យបាក់បបខ្ទបខ្ទាច ចុះចាញ់បរមត្ថបារមីរបស់ព្រះអង្គ ហើយទ្រង់រំពឹងដល់ពុទ្ធប្បវេណី ដោយឈានសមាបត្តិលះបង់នូវ រាគះ ទោសះ មោហះ មានះ ទិដ្ឋិ ព្រមទាំង កិលេស តណ្ហា គ្រប់ជំពូកឱ្យឃ្លាតចាកជាស្ថាពរពីសន្តានព្រះអង្គ ។

---

[១] ក្នុងសៀវភៅ "**ព្រះនិព្វាន គោលបំផុតរបស់ព្រះពុទ្ធសាសនា**" ដោយភិក្ខុ **នារទ ថេរៈ** បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥០៣ បានសរសេរថា : "**សោបាទិសេស** និង **អនុបាទិសេសធាតុ**"។ តាមដោយពិតនោះ មិនមែនមានព្រះនិព្វាន ២ យ៉ាងនោះទេ គឺមានតែម្យ៉ាងប៉ុណ្ណោះ ប៉ុន្តែព្រះនិព្វានទទួលនាមបញ្ញត្តិតាមលំអានដែលបានដឹងច្បាស់ **ជាមុន** និង **ជាក្រោយ** នៃសេចក្តីស្លាប់ ។

# សច្ចធម៌ និង ពុទ្ធិគតិបណ្ឌិត

នៅពេលនោះ ព្រះពុទ្ធអង្គទ្រង់ព្រះបន្លឺនូវព្រះឧទានវាចាថាៈ កាលដែលតថាគតកំពុងស្វែងរកជាងឈើ គឺ **តណ្ហា**, អ្នកធ្វើនូវផ្ទះ គឺ **អត្តភាព**របស់តថាគត កាលដែលមិនទាន់បានរកឃើញនូវ"សច្ចធម៌" នៅឡើយ តថាគតតែងអន្ទោលវិលវល់ក្នុងវាលវដ្តសង្សាររាប់ជាតិ ដ៏ច្រើន, ជាតិក៏តែងនាំមកនូវសេចក្តីទុក្ខរាប់មិនអស់ **នែ៎ជាងផ្ទះ!** ឥឡូវតថាគតស្គាល់អ្នកច្បាស់ ដឹងនូវពុតត្បុតកលល្បិច មាយារបស់អ្នកអស់ហើយ អ្នកឯងអស់បានធ្វើផ្ទះ គឺអត្តភាពឱ្យតថាគតបានទៀតហើយ, បង្កង់ គឺ**កិលេស**សេសសល់ទាំងឡាយរបស់អ្នកឯង តថាគតកាច់បំបាក់អស់ហើយ, ទាំងកំពូលផ្ទះ គឺ **អវិជ្ជា** ដែលអ្នកឯងធ្វើរួចហើយ តថាគតក៏បានកំចាត់បង់ហើយដែរ ។ **ឥឡូវនេះចិត្តតថាគតបានដល់ព្រះនិព្វាន** ដែលប្រាសចាកនូវសង្ខារធម៌ជាគ្រឿងសៅហ្មងទាំងឡាយហើយ តថាគតបានរកឃើញនូវចតុរារិយសច្ចធម៌ និងត្រាស់ដឹងនូវគុណធម៌ដ៏ខ្ពង់ខ្ពស់ទាំងឡាយ ដែលជាធម៌កំចាត់បង់នូវតណ្ហាទាំងឡាយ ដែលជាប្រភពនៃសេចក្តីទុក្ខហើយ ។

ផ្លូវព្រះនិព្វាន បានដល់មោក្ខធម៌ ៨ គឺ **មគ្គ ៤** និង **ផល ៤** (**<u>លោកុត្តរចិត្ត</u>** : ចិត្តដ៏ប្រសើរឧត្តុង្គឧត្តមដែលឆ្លងផុតចាកវដ្តសង្សារពោលគឺ ភាពអវិជ្ជា តណ្ហា និង ឧបាទាន ) ។

| **មគ្គ ៤** | **ផល ៤** |
|---|---|
| សោតាបត្តិមគ្គ | **សោតាបត្តិផល** |
| សកទាគាមិមគ្គ | **សកទាគាមិផល** |
| អនាគាមិមគ្គ | **អនាគាមិផល** |
| អរហត្តមគ្គ | **អរហត្តផល** |

១ - សោតាបត្តិមគ្គ < សោត: *ស្តាប់* + អាបត្តិ *កិរិយាត្រូវ, ត្រូវហើយ ឬការដល់, ការដល់ជាដំបូង* + មគ្គ *ផ្លូវ* : ពោលគឺកិរិយាស្តាប់យល់ដឹងបាននូវ **សច្ចធម៌,** ជាវិថីនៃចិត្តជាថ្នាក់ដំបូង ឬជាការចាប់ផ្តើមចេញដំណើរឆ្ពោះទៅកាន់ព្រះនិព្វាន ដោយកុក្កុរកុសលចិត្តរបស់ព្រះអរិយបុគ្គល ដោយនៅមានបដិសន្ធិក្នុងលោកតទៅទៀត (*នៅត្រឡប់មកកើតក្នុងស្ថានមនុស្សមិនហួសពី ៧ ជាតិទៀត*) តាមវិថីជីវិតដែលប្រកបដោយអង្គប្រតិបត្តិទាំង ៨ នៃ **អដ្ឋង្គិកមគ្គ** ឬ **មជ្ឈិមប្បដិបទា** (មាគ៌ាឧបេក្ខា_មាគ៌ាកណ្តាល)។

២ - សកទាគាមិមគ្គ < សកឹ *អស់វារៈម្តង* + អាគាមី *ត្រឡប់មករក* + មគ្គ *ផ្លូវ* : ចិត្តជាលំដាប់ថ្នាក់ទី ២ របស់អរិយបុគ្គលដែលត្រូវមកកាន់មនុស្សលោកយើងនេះដោយអំណាចនៃបដិសន្ធិ អស់វារៈម្តងទៀត ទើបសម្រេចបានដល់នូវព្រះនិព្វាន ។

៣ - អនាគាមិមគ្គ < អន **មិន...** មិនមែន មិនមាន, + អាគាមី ត្រឡប់មក + មគ្គ *ផ្លូវ* : បានសេចក្តីថា ចិត្តដែលប្រកបព្រមដោយគុណធម៌របស់ព្រះអរិយបុគ្គលទាំងឡាយ លែងវិលត្រឡប់មកកាន់កំណើតមនុស្សលោកយើងនេះដោយអំណាចនៃបដិសន្ធិទៀតហើយ, បានដល់លំដាប់ចិត្តកម្រិតជាន់ទី ៣ របស់ព្រះអរិយបុគ្គល ដែលមាន

កំណើតនៅក្នុងព្រហ្មលោកតែប៉ុណ្ណោះ រួចហើយឆ្ពោះត្រង់ទៅព្រះនិព្វានតែម្តង ។

៤- អរហត្តមគ្គ : ភាពនៃចិត្តរបស់បុគ្គលដែលគប្បីបានទទួលនូវការគោរពបូជាដ៏ថ្លៃថ្លា, ជាវិថីនៃចិត្តរបស់ព្រះអរិយបុគ្គលដែលឡើងដល់ថ្នាក់ជាន់ទី ៤, ឆ្លងផុតចាកកងទុក្ខទាំងពួង លែងកើតទៀតហើយរង់ចាំតែពេលវេលាទម្លុះកាយ ទម្លាយខន្ធ ទៅកាន់ព្រះបរមនិព្វានបរមសុខតែប៉ុណ្ណោះ ។

➪ **អនុបាទិសេសនិព្វាន** គឺជាលោកុត្តរនិព្វាន បានដល់សភាវធម៌ចេញរួចចាកផុតទាំងស្រុង ពីគ្រឿងចាក់ស្រេះគឺតណ្ហា និង **រលត់ព្រមនូវខន្ធទាំង ៥** និង **កងទុក្ខ** ដោយគ្មានសេសសល់ឡើយ, ដូចជាព្រះជិនស្រីដែលទ្រង់បានដល់នូវព្រះសព្វញ្ញុតញ្ញាណ ទ្រង់គង់ប្រោសសត្វបាន ចំនួន ៤៥ ព្រះវស្សា ព្រះអង្គទ្រង់យាងផ្ទុំលើទែនសីលាសនៈ ក្រោមដើមសាលព្រឹក្សទាំងគូក្បែរនគរកុសិនារាហើយទ្រង់យាងចូលកាន់ឈានសមាបត្តិ ដាក់ព្រះជន្មាយុសង្ខារ និង ទ្រង់ព្រះដំណើរចូលកាន់ព្រះបរិនិព្វាន ពោលគឺរំលត់ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ឥតមាន **វិបាកក្ខន្ធ** និង **កម្មជរូប** នៅសេសសល់ឡើយ ។

# សច្ចធម៌ និង ពុទ្ធិគតិបណ្ឌិត

## ក្នុងរូបភាពនេះ បានបង្ហាញអោយយើងឃើញ នូវ :

- ផ្ទៃខ្មៅងងឹត គឺជាភាពអវិជ្ជា ដែលគ្របដណ្តប់ បិទបាំង ចិត្ត គំនិតមនុស្ស-សត្វនិករ ក្នុងវាលវដ្តសង្សារនេះ មិនអោយមើលឃើញសច្ចធម៌ ។
- ច្រវាក់នៃតណ្ហាដែលចងក្រៀកចាក់ស្រេះជីវិតក្នុងវដ្តសង្សារ,
- បង្គោលស្នឹងដែលចងដោតភ្ជាប់នឹងច្រវាក់នោះគឺ **ឧបាទាន** នេះឯង ដែលធ្វើអោយមនុស្សជាប់ជំពាក់ជារៀងរហូតនោះ ។



## សច្ចធម៌ និង ពុទ្ធិគតិបណ្ឌិត

សភាវៈទាំងបី (អវិជ្ជា តណ្ហា ឧបាទាន ) ជាហេតុធ្វើអោយជីវិតមនុស្ស-សត្វ លង់ក្នុងសមុទ្រវាលវដ្តសង្សារ ងងឹតសូន្យសុងគ្មានពន្លឺ ។ យើងត្រូវតែខំប្រយុទ្ធកាត់ផ្តាច់ កាច់បំបាក់នូវចំណងច្រវាក់ គាស់រំលើងនូវបង្គោលស្នឹង និង រំលាយដុំខ្មៅអន្ធការនេះ ដោយការប្រតិបត្តិខ្ជាប់ខ្ជួននូវ **សីល សមាធិ បញ្ញា** នោះទើបយើងជួបនឹងពន្លឺព្រះនិព្វានបាន ។

## ទសបារមី ឬគុណធម៌ដ៏កំពូល ១០យ៉ាង :

១. ទានបារមី : គុណធម៌នៃការបំពេញទាន គឺការបរិច្ចាគ ។
២. សីលបារមី : គុណធម៌នៃការកសាង រក្សា សីល ។
៣. នេក្ខម្មបារមី : គុណធម៌នៃការចេញចាកកាម ។
៤. បញ្ញាបារមី : គុណធម៌នៃការស្គាល់ហេតុ-ផលច្បាស់លាស់
៥. វីរិយបារមី : គុណធម៌នៃការសន្សំការព្យាយាមតស៊ូ ។
៦. ខន្តិបារមី : គុណធម៌នៃការបំពេញសេចក្តីអំណត់ ។
៧. សច្ចបារមី : គុណធម៌នៃការរក្សាសេចក្តីពិតទៀងត្រង់។
៨. អធិដ្ឋានបារមី: គុណធម៌នៃការតាំងចិត្តរឹងមាំ ខ្ជាប់ខ្ជួន ។
៩. មេត្តាបារមី : គុណធម៌នៃការបំពេញ ផ្សព្វផ្សាយមេត្តាធម៌។
១០. ឧបេក្ខាបារមី : គុណធម៌នៃការតាំងចិត្តជាកណ្តាលស្មើ ។

បារមីទាំង ១០ ប្រការនេះ គឺជាគុណធម៌ដ៏កំពូល ដែលព្រះពុទ្ធអង្គទាំងឡាយ បានខិតខំព្យាយាមសាងបំពេញ ដោយខ្ជាប់ខ្ជួន ក្នុងជីវភាពជាពោធិសត្វ ។

**បារមី** គឺជាគុណជាតិដ៏ល្អប្រសើរវិសេសវិសាល ដែលបុគ្គលគួរបំពេញអោយបាននូវកុសលធម៌ ជាគុណប្រយោជន៍ដល់ខ្លួនឯងផង ដល់សង្គមមនុស្ស សង្គមជាតិផង ដោយការសំអិតសំអាត កិរិយា ចរិយា មារយាទ អោយស្អាតល្អបរិសុទ្ធផូរផង់ ដោយ **សីល សមាធិ បញ្ញា** ពេញលេញ សុក្រឹតគ្មានខ្វះចន្លោះ គ្មានល្អក់កករ ។

**បារមី** មាន ៣ លំដាប់ថ្នាក់ : ថ្នាក់ដំបូង គឺ **បារមី** ឬ **បឋមបារមី**, ថ្នាក់កណ្តាល គឺ **ឧបបារមី** និង ថ្នាក់ខ្ពស់កំពូល ហៅថា **បរមត្ថបារមី** ។

សច្ចធម៌ និង ពុទ្ធិគតិបណ្ឌិត

# មង្គលជីវិត

( អំពើល្អជាសិរីនៃជីវិត ជាគុណធម៌លំអជីវិត )

( ដកស្រង់ចាកពី មង្គលសូត្រ )

ប្រមូលរៀបរៀង ដោយ ព្រហ្ម~មេត្តា (ហៅ ជ័យទរិទ្ធ)

# មង្គល ៣៨ ប្រការ

## ៚ មង្គលទី ១ :

- **អសេវនា ច ពាលានំ,**

- កិរិយាមិនសេពគប់នូវបុគ្គលពាលទាំងឡាយ

ជាមង្គលដ៏ឧត្តម ។

## ៚ មង្គលទី ២ :

- **បណ្ឌិតានញ្ច សេវនា,**

- កិរិយាសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ

ជាមង្គលដ៏ឧត្តម ។

## ៚ មង្គលទី ៣ :

- **បូជា ច បូជនីយានំ,**

- កិរិយាបូជាដល់បុគ្គលដែលគួរគោរពបូជាទាំងឡាយ

ជាមង្គលដ៏ឧត្តម ។

## ❀ មង្គលទី ៤ :

~ **បដិរូបទេសវាសោ ច,**

កិរិយានៅក្នុងប្រទេសដ៏សមគួរ

ជាមង្គលដ៏ឧត្តម ។

## ❀ មង្គលទី ៥ :

~ **បុព្វេ ច កតបុញ្ញតា,**

- ភាវៈនៃបុគ្គលបានធ្វើបុណ្យទុកហើយក្នុងកាលមុន

ជាមង្គលដ៏ឧត្តម !

## ❀ មង្គលទី ៦ :

~ **អត្តសម្មាបណិធិ ច,**

- កិរិយាតម្កល់ខ្លួនទុកដោយប្រពៃ

ជាមង្គលដ៏ឧត្តម !

## ❀ មង្គលទី ៧ :

~ **ពាហុសច្ចំ,**

- ការបានស្ដាប់ បានរៀនចេះចាំច្រើន

ជាមង្គលដ៏ឧត្តម !

ꩰ **មង្គលទី ៨** :

- **សិប្បៈ,**

- សេចក្តីឆ្លៀវឆ្លាសក្នុងសិល្បសាស្ត្រវិជ្ជាការទាំងពួង

ជាមង្គលឧត្តម !

ꩰ **មង្គលទី ៩** :

- **វិនយោ ច សុសិក្ខិតោ,**

- វិន័យដែលបុគ្គលសិក្សាដោយប្រពៃហើយ

ជាមង្គលដ៏ឧត្តម !

ꩰ **មង្គលទី ១០** :

- **សុភាសិតា ច យា វាចា,**

- វាចាដែលបុគ្គលពោលដោយប្រពៃ ប្រកបដោយគុណប្រយោជន៍ ជាមង្គលដ៏ឧត្តម !

៙ **<u>មង្គលទី ១១-១២</u>** :

~ **មាតាបិតា ឧបដ្ឋានំ,**

- ការបម្រើមាតា-បិតាជាអ្នកមានគុណ

ជាមង្គលដ៏ឧត្ដម !

៙ **<u>មង្គលទី ១៣</u>** :

~ **បុត្តទារស្ស សង្គហោ,**

- ការសង្គ្រោះចំពោះបុត្រ និង ភរិយា

ជាមង្គលដ៏ឧត្ដម !

៙ **<u>មង្គលទី ១៤</u>** :

~ **អនាកុលា ច កម្មន្តា,**

- ការងារមិនច្របូកច្របល់ គឺធ្វើការងារដាច់ស្រេច

ជាមង្គលដ៏ឧត្ដម !

## ៙ **មង្គលទី ១៥** :

- **ទានំ,**
- ការផ្តល់នូវទាន (ពិសេសធម្មទានសច្ចធម៌)

ជាមង្គលដ៏ឧត្តម !

## ៙ **មង្គលទី ១៦** :

- **ធម្មចរិយា,**
- ការប្រព្រឹត្តនូវធម៌ ជាមង្គលដ៏ឧត្តម !

## ៙ **មង្គលទី ១៧** :

- **ញាតកានញ្ច សង្គហោ,**
- ការសង្គ្រោះញាតិទាំងឡាយ ជាមង្គលដ៏ឧត្តម !

## ៙ **មង្គលទី ១៨** :

- **អនវជ្ជានិ កម្មានិ,**
- ការងារទាំងឡាយ ដែលមិនមានទោស

ជាមង្គលដ៏ឧត្តម !

៙ **មង្គលទី ១៩** :

~ **អារតី វិរតីបាបា,**

- ការមិនត្រេកអរក្នុងបាប និង កិរិយាវៀរចាកបាប

ជាមង្គលដ៏ឧត្តម !

៙ **មង្គលទី ២០** :

~ **មជ្ជបានា ច សញ្ញមោ,**

- សេចក្ដីសង្រួម ចាកកិរិយាផឹកនូវទឹកស្រវឹង

ជាមង្គលដ៏ឧត្តម !

៙ **មង្គលទី ២១** :

~ **អប្បមាទោ ច ធម្មេសុ,**

- សេចក្ដីមិនប្រមាទក្នុងធម៌ទាំងឡាយ

ជាមង្គលដ៏ឧត្តម !

៙ **មង្គលទី ២២** :

~ **គារវោ ច,**

- សេចក្ដីគោរព ក្នុងបុគ្គលដែលគួរគោរព

ជាមង្គលដ៏ឧត្តម !

**៙ មង្គលទី ២៣ :**

- **និវាតោ ច,**

- កិរិយាប្រព្រឹត្តជីវិតរស់នៅដោយសាមញ្ញ សុភាពរាបសា (*ការលះបង់ចោលនូវសក្កាយទិដ្ឋិ និង អស្មិមានះ ចេញចាកសន្តាន*)

ជាមង្គលដ៏ឧត្តម !

**៙ មង្គលទី ២៤ :**

- **សន្តុដ្ឋី ច,**

- សេចក្តីត្រេកអរចំពោះរបស់ដែលមាន

ជាមង្គលដ៏ឧត្តម !

**៙ មង្គលទី ២៥ :**

- **កតញ្ញុតា,**

- ភាពនៃបុគ្គលជាអ្នកដឹងនូវឧបការគុណដែលអ្នកដទៃធ្វើហើយដល់ខ្លួន ជាមង្គលដ៏ឧត្តម !

## ៙ មង្គលទី ២៦ :

~ **កាលេន ធម្មស្សវនំ,**

- បុគ្គលបានស្តាប់ធម៌រឿយៗ តាមកាល

ជាមង្គលដ៏ឧត្តម !

## ៙ មង្គលទី ២៧ :

~ **ខន្តិ ច,**

- សេចក្តីអត់ធន់ ជាមង្គលដ៏ឧត្តម !

## ៙ មង្គលទី ២៨ :

~ **សោវចស្សតា,**

- ការធ្វើខ្លួនអោយទៅជាបុគ្គលងាយប្រដៅ ងាយអប់រំ តាមគន្លងគុណធម៌ ជាមង្គលដ៏ឧត្តម !

## ៙ មង្គលទី ២៩ :

~ **សមណានញ្ច ទស្សនំ,**

- កិរិយាបានឃើញ បានជួបនូវសមណៈទាំងឡាយ ដែលមានឥន្ទ្រិយស្ងប់រម្ងាប់ហើយ ជាមង្គលដ៏ឧត្តម !

ஜ **មង្គលទី ៣០** :

- **កាលេន ធម្មសាកច្ឆា,**

- កិរិយាសន្ទនាសាកសួរនូវធម៌តាមកាល

ជាមង្គលដ៏ឧត្តម !

ஜ **មង្គលទី ៣១** :

- **តបោ ច,**

- សេចក្តីព្យាយាមដុតនូវបាបធម៌ពោលគឺញាំងកិលេស ដែលមាននៅក្នុងខន្ធសន្តានអោយរីងស្ងួតបាន

ជាមង្គលដ៏ឧត្តម !

ஜ **មង្គលទី ៣២** :

- **ព្រហ្មចរិយញ្ច,**

- កិរិយាប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ជាមង្គលដ៏ឧត្តម !

ꕥ **<u>មង្គលទី ៣៣</u>** :

~ **អរិយសច្ចាន ទស្សនំ,**

- កិរិយាឃើញនូវអរិយសច្ចៈ (ការពិតដ៏ប្រសើរទាំង៤) ទាំងឡាយ ជាមង្គលដ៏ឧត្តម !

ꕥ **<u>មង្គលទី ៣៤</u>** :

~ **និព្វានសច្ឆិកិរិយា ច,**

- កិរិយាធ្វើនូវព្រះនិព្វានអោយជាក់ច្បាស់បាន ដោយបញ្ញា ជាមង្គលដ៏ឧត្តម !

ꕥ **<u>មង្គលទី ៣៥</u>** :

~ **ផុដ្ឋស្ស លោកធម្មេហិ ចិត្តំ យស្ស នកម្បតិ,**

- ចិត្តរបស់បុគ្គលឯណា ដែលមិនញាប់ញ័រ ដោយលោកធម៌ទាំងឡាយ ហើយយល់ត្រូវ (សម្មាទិដ្ឋិ) ជាមង្គលដ៏ឧត្តម !

| លោកធម៌ ៨ ដែលអន្ទងនចិត្តមនុស្សអោយជោរ ញាប់ញ័រ | | | |
|---|---|---|---|
| សភាវៈធ្វើអោយចិត្តជោរ | | សភាវៈធ្វើអោយចិត្តធ្លាក់ធន់ | |
| ១ | **លាភ** ( បានលាភ ) | ២ | **អលាភ** ( បាត់លាភ ) |
| ៣ | **យស** ( បានយស ) | ៤ | **អយស** ( បាត់យស ) |
| ៥ | **សុខ** ( បានសុខ ) | ៦ | **ទុក្ខ** ( មានទុក្ខ ) |
| ៧ | **សរសើរ** | ៨ | **និន្ទា** ( ប្រណែន ) |

## ៙ មង្គលទី ៣៦ :

~ **អសោកំ,**

- សេចក្ដីមិនសោយសោកដោយហេតុដែលកើតឡើងផ្សេងៗ ជាមង្គលដ៏ឧត្តម !

## ៙ មង្គលទី ៣៧ :

~ **វិរជំ,**

- ចិត្តដែលប្រាសចាកធូលី គឺកិលេសក្នុងសន្ដាន ជាមង្គលដ៏ឧត្តម !

៩០ **<u>មង្គលទី ៣៨</u>** :

- **ខេមំ,**

- អ្នកដែលមានសេចក្តីក្សេម ចាកយោគៈជាគ្រឿង ប្រកបចងរឹតរួតក្នុងសន្តាន ជាមង្គលដ៏ឧត្តម !

# ពិចារណាពីជីវិត

៙ ធាតុបួនរលត់ ពន្លត់ជីវិត
អនត្តាមែនពិត ឥតមានសល់អ្វី
ពេលរស់ចម្រាញ់ ប្ដូមខ្វាញ់ផែនដី
ស្លាប់លាលោកិយ ចំណីពសុធា ។

៙ ថ្ងៃល្ងាចយប់ព្រឹក រំលឹកប្រាប់មនុស្ស
ជីវិតរលស់ អស់តាមវេលា
រស់បានមួយថ្ងៃ ខិតខំខ្វីជន្មា
កុំពុលមាយា អវិជ្ជាទុរយស ។

៙ ស៊ូរស់បរិសុទ្ធ បន្សុទ្ធបញ្ញា
ភ្លឺថ្លាសតិ ឥស្សរភាពខ្ពស់
**រស់ជាអ្នកជា មានគុណកិត្តិយស**
**ស្លាប់ក្រអូបឈ្មោះ រស់ក្រអូបចិត្ត !**

**ព្រហ្ម មេត្តា**

# រៀនស្លាប់ !

~ បានកើតរស់រាន  កុំមានប្រមាទ
រស់រៀនសំអាត  អោយស្អាតគំនិត
រៀនរស់រៀនស្លាប់  ប្រាប់ដល់ជីវិត
ស្លាប់មានមែនពិត  ឥតប្រាប់ពេលណា ។

~ បើដឹងថាស្លាប់  ប្រញាប់សាងល្អ
បណ្តុះគុណធម៌  ស្មោះសរចិន្តា
ស្លាប់ក្រអូបឈ្មោះ  ព្រោះឈ្នះតណ្ហា
រស់ច្បាំងអាត្មា  មរណាជោគជ័យ !

~ មរណាជោគជ័យ  មានន័យពីរោះ
ពង្រោះកេរ្តិ៍ឈ្មោះ  រស់ជាប់ខែថ្ងៃ
ជនទាំងឡាយអើយ  ដឹងហើយខំថ្នៃ
រៀនស្លាប់អោយថ្លៃ  មានន័យពីរោះ !

# ឯកសារពិគ្រោះ


១. ទស្សនៈសម្ដេចព្រះសង្ឃរាជ ជួន-ណាត ..... ព្រះមុនីកោសល **សូរ-ហាយ**

២. ប្រជុំកថធម៌សម្រាប់សាលាធម្មវិន័យ .................................. ថ្នាក់ត្រី

៣. ប្រស្នាអភិធម្មពិស្ដារ ........................................................ **សែម-សូរ**

៤. អភិធម្មសង្ខេប ផ្នែកបរមត្ថ ...................... ភិក្ខុមហា **សោម-សុវណ្ណ**

៥. អធិប្បាយប្រជុំកថធម៌ពិស្ដារ ភាគ១-២ .......... បណ្ឌិត **ឈឹម-ទូច**

៦. ត្រៃលក្ខណប្រទីប ........................................... ឧត្ដមលិខិត **សុខ-ស៊ីវ**

៧. ប្រស្នាត្រៃគុណ ........................................... លោកអាចារ្យ **ឈឹម ទូច**

៨. សំដែងពីព្រះនិព្វាន ........................................................ ភិក្ខុ **នារទ ថេរ:**

៩. នរក សួគ៌ និព្វាន ................................................ អ្នកឧកញ៉ា **ធា-សាន**

១០. និព្វាននៅឯណា? ..................................................... ធម្មបាល **ខៀវ-ជុំ**

១១. អនត្តាធម៌ និព្វានធម៌ ............................................ ព្រះឧត្ដមមុនី **អ៊ុំ-ស៊ុំ**

១២. ទ្រឹស្ដីកម្ម-ផល ....................... រៀបរៀងដោយលោក **ឈុន-គិមអឿត**

១៣. សីលនិទ្ទេស ................................................ ហ្លួងវិសុទ្ធមេធា **អ៊ុច-រស់**

១៤. សមាធិនិទ្ទេស ........................................... ព្រះគ្រូវីរិយមុនីវិសុទ្ធញាណ

១៥. បញ្ញានិទ្ទេស ........................................................ អាចារ្យ **ឈឹម-ទូច**

១៦. មង្គលសូត្រ ៣៨ ប្រការ ................................ ព្រះវិន័យធរ **ឯក-ញឹម**

១៧. *L'Enseignement du Bouddha* ........... Editions du Seuil

១៨. **No "I" in the World** ........................................ Varadhamma

# សច្ចធម៌ និង ពុទ្ធិគតិបណ្ឌិត

## ខ្ញុំសូមលំអោនកាយដោយសេចក្តីគោរពបំផុត

## សូមឧទ្ទិសនូវកុសល_ផលបុណ្យទាំងឡាយ

ដែលកើតបានមកពីសេចក្តីព្យាយាមប្រមូល ចងក្រង រៀបរៀង

សៀវភៅ "**សច្ចធម៌** និង **ពុទ្ធិគតិបណ្ឌិត**" នេះ

ទុកជាសេចក្តីកត្តញ្ញូកតវេទី ដោយសេចក្តីគោរពបំផុត

ជូនចំពោះ **ព្រះគុណទាំង ៣** (ត្រៃគុណ) :

**_ លោកឳពុក_អ្នកម្តាយ និង បុព្វការីជនទាំងអស់ !**




ខ្ញុំ **ជ័យវរិន្ទ (ព្រហ្ម_មេត្តា)** គោរពកេសា ថ្វាយបង្គំសពលោកឳពុក ដែលទទួលអនិច្ចកម្មកាលពីថ្ងៃអង្គារ ៩ កើត ខែបុស្ស ឆ្នាំ វក ឆស័ក ព.ស. ២៥៤៨ // ត្រូវនឹង ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៥ ។

## ~ គុណគ្រូបាធ្យាយទាំងអស់...



<u>**រូបថត**</u> : ខ្ញុំ **វណ្ណ~សុភា** (ជ័យវរិន្ទ ) និង បងស្រី **វណ្ណ~មុនី** និង ក៏ជាអ្នកគ្រូរបស់ខ្ញុំផងដែរ (*កាលពីខ្ញុំរៀននៅសាលាបឋមសិក្សាកណ្តាល កោះសូទិន* ) ថ្វាយបង្គំព្រះសព ព្រះគ្រូ សម្តេចព្រះមង្គលទេពាចារ្យ **អ៊ុំ~ស៊ុំ** នៅវត្តមហាមន្ត្រី ក្រុងភ្នំពេញ ( ព.ស. ២៥៤៤ / គ.ស. ២000 ) ។

# សច្ចធម៌ និង ពុទ្ធិគតិបណ្ឌិត

## ~ ចំពោះលោកគ្រូ~អ្នកគ្រូ និង លោក~អ្នកមានឧបការគុណទាំងអស់ !



**រូបថត** : ជាមួយលោកគ្រូ លោកព្រឹទ្ធាចារ្យ **ឆេង~ផុន** នៅអាស្រម
វិលត់ទុក្ខ ព្រែកហូរ តាខ្មៅ_ខេត្តកណ្ដាល
(ព.ស. ២៥៣៤ / គ.ស. ១៩៩១)

# អវសានកថា

- រូបកាយបាត់ទៅទុកនៅពាក្យពេចន៍ រំលេចដោយធម៌ ស្មោះសរគំនិត
**មរតកសច្ចៈ គតបណ្ឌិត** កំណាប់គំនិត គាស់គិតចម្លើយ ។
- រស់រៀនហាត់ស្លាប់ប្រញាប់រួតរះ ហ្វឹកហាត់កាត់លះផ្សះចិត្តឱ្យស្បើយ
បណ្តាំចុងក្រោយកុំប្រមាទឡើយ ហាត់ស្លាប់ឱ្យហើយជីវិតមិនទៀង ។
- ដំណើរជីវិត ប្រព្រឹត្តតាមកម្ម ប្រែប្រួលប្រចាំ កម្មអ្នករៀបរៀង
តណ្ហាលោកិយ បីដូចចម្រៀង លួងលៀងច្រៀងលោមទ្រោមជាប់ចំណង ។
- របស់ក្នុងលោករកខ្លឹមសារគ្មាន មានដូចមិនមាន វានៈគ្រឿងចង
តែមិនហាត់លះច្បាស់ជាប់ចំណង តណ្ហាដោតក្រង ចងចិត្តកម្លៅ ។
- នាមរូបខ្ចីបុល បំណុលវដ្តៈ មិនស្គាល់ធម្មៈ អវិជ្ជាល្ងង់ខ្លៅ
បបញ្ចធម៌ ត្រាច់ចរសំដៅ ធ្លាក់ក្នុងជ្រោះជ្រៅ លំនៅវដ្តៈ ។
- អវិជ្ជាមិនដឹង ស្រវឹងនឹងអញ ទិដ្ឋិប្រវ័ញ្ច បញ្ចក្ខន្ធភារៈ
មិនស្គាល់នាម-រូប ជួបជាប់ជំពាក់ ដើរចូលអន្ទាក់ ធ្លាក់មច្ចុរាជ ។
- ចម្រើនបញ្ញា ប្រហារអវិជ្ជា លះលោកមាយា ភាវនាព្រឹកល្ងាច
ដឹងច្បាស់លោកិយ បុរីមច្ចុរាជ រស់មិនប្រមាទ សម្អាតជីវិត !

☸ *ពេលមានជីវិតរស់នៅ...ត្រូវរៀនរស់...ហើយព្រមស្លាប់...*
*ត្រៀមស្លាប់... ហើយហាត់ស្លាប់... ដើម្បីសម្លាប់សេចក្តីស្លាប់!*

© ធម្មទស្សនទាន

**ព្រហ្ម-មេត្តា គតបណ្ឌិតោ** (ហៅ **ជយវិន្ទ**)

"គុណធម៌"
ជាសារជាតិរបស់ពពួកបណ្ឌិត!

# គុណធម៌

~ ស្គាល់ត្រៃគុណ នរជននោះ ឈ្មោះបណ្ឌិត
ព្រោះគំនិត គិតឃើញត្រូវ ផ្លូវកុសល
មានគុណធម៌ ល្អថ្លាថ្លៃ គ្មានអ្វីដល់
ស្គាល់ហេតុ-ផល យល់ដឹងច្បាស់ ព្រះគុណបី!

~ កើតមកបានរស់ ព្រោះគុណឪម៉ែ
លោកថ្នាក់ថ្នមថែ ចិត្តស្នេហ៍ប្រណី
ធំឡើងទៅរៀន មានវិជ្ជាល្បី
គុណគ្រូប្រុសស្រី គួរលៃគោរព ៗ

~ មិត្តមាជួនគា បុព្វការីជន
ជួយប្រឹងរែកពុន ចាកខ្មៅឧបទ្រព
គុណថ្លៃទាំងបី ប្រពៃដូចម្លប់
ត្រូវដាក់ថ្ងៃយប់ គឺម្លប់ព្រះធម៌!

និពន្ធដោយ វណ្ណ-សុភា ហៅ ជយវិន្ទ



ទានសច្ចធម៌ (ព្រះធម្មទាន)
ប្រសើរលើសទានដទៃទាំងពួង!

# សច្ចធម៌

~ កើតមកជាមនុស្ស រស់មានជីវិត
ត្រូវស្គាល់ការពិត គិតដឹងហេតុ-ផល
អវិជ្ជាដើមចម នាំចិត្តអកុសល
តណ្ហានាំខ្វល់ ផ្តល់ឧបាទាន !

~ បើស្គាល់សច្ចៈ ភ្ញាក់រឭកត្រូវ
ព្រះធម៌ជាផ្លូវ នាំទៅនិព្វាន
សីលប្រាំចាំជាប់ អប់រំសីលទាន
ព្រះធម៌ទូន្មាន រៀនគិតយប់ថ្ងៃ ៗ

~ ព្រះធម៌វិន័យ ខន្តីរស់នៅ
គុណធម៌ជ្រាលជ្រៅ ផ្លូវកុសលបី
ស្គាល់សច្ចធម៌ ត្រេចចរយប់ថ្ងៃ
ដូចមានរស្មី បំភ្លឺជីវិត !

និពន្ធដោយ ជយវិន្ទ ហៅ ព្រហ្ម-មេត្តា

© "មណ្ឌលពុទ្ធិ ត្រៃគុណ"
ទីជួបគ្នាដើម្បីស្វែងរកចំណេះដឹង និង គតិបណ្ឌិត

~ ការមិនសេពគប់មនុស្សពាល, ការសេពគប់ជនជាបណ្ឌិត
ការគោរពបូជាចំពោះបុគ្គលដែលគួរគោរពបូជា នេះជាមង្គលដ៏ឧត្តម!

(ស្រង់ចាកមង្គលសូត្រ)